## រឿង

# ឃជួបបំណង


អ្នកនិពន្ធ

**លឹម លាងជិន**


**គ.ស ១៩៦៥**


បោះពុម្ពផ្សាយជាថ្មីដោយ

**លោក ស្រី ប៊ុនជន**

**ភ្នំពេញ, ថ្ងៃទី ១០ មេសា ២០០៥**



**រក្សាសិទ្ធិ**

# កថាមុខ

ក្នុងគោលបំណងចង់បំរើអារម្មណ៍លោក អ្នកនាង កញ្ញា ក្នុងការអាន សៀវភៅប្រលោមលោក លេងកំសាន្តពេលសំរាក ឱ្យមានឧត្តមគតិស្របតាម គោលគំនិតសម័យនិយម ខ្ញុំសូមឧទ្ទិសសៀវភៅរឿង **"បានដូចបំណង"** នេះ ឱ្យបានជាមិត្តដ៏ប្រសើររបស់លោកអ្នកអាន ។

រឿង **"បានដូចបំណង"** ជាកម្រងរឿងប្រឌិតឡើងតាមមនោ សញ្ចេតនាពិត១ ហើយខ្ញុំសង្ឃឹមថាគ្រប់ទំព័រនៃសៀវភៅរឿងនេះ នឹងបានណែ នាំសតិអារម្មណ៍លោកអ្នកនាងកញ្ញាឱ្យជប់ជាប់នឹងពាក្យពេជ្យលាតត្រដាងនូវ ជីវិតរស់នៅនៃជនជាតិយើងឯតំបន់ស្រុកភ្នំ ។

ម្យ៉ាងទៀត សូមឱ្យបងប្អូនខ្មែរលើមានជោគជ័យក្នុងការសិក្សា ដើម្បី ឱ្យបានជាពលរដ្ឋដ៏ល្អ ស្គាល់ការស៊ីវិល័យចេះរួបរួមនិរន្តជុំវិញព្រះរាជបល្លង្គឱ្យ សមជាពលរដ្ឋក្នុងសម័យសម្តេចព្រះបាទនរោមត្តសីហនុ ព្រះបិតាឯករាជ្យជាតិ ។

ភ្នំពេញ, ថ្ងៃទី ១៣ តុលា ឆ្នាំ ១៩៦៥

លឹម លាងជិន

## ១

## កិត្តិសព្ទអ្នកតស៊ូ

ទ្វារផ្ទះទាំងឡាយនៅទីក្រុងក្រចេះ បានបើកគ្រប់ៗល្វែង ហើយព្រឹក នេះព្រះអរុណចោលរស្មីភ្លឺថ្លា ខ្យល់បក់រំភើយ១ត្រជាក់គួរឱ្យជាទីមនោរម្យ, នរណាមិនមានចិត្តរីករាយ នឹងធម្មជាតិបែបនេះ? កុមារាកុមារីស្រែកហ៊ោ កញ្ច្រៀវ លោតកញ្ឆែង លាន់ឮសូរស័ព្ទរំពងរកស្តាប់អ្វីមិនបាន ព្រោះគេមិនទាន់ដល់ម៉ោងចូលរៀន។ នៅតាមផ្លូវមុខសាលារៀននេះ មានជនខ្មែរលើមួយរូប ស្លៀកពាក់ពុំសមសួន ដៃកាន់បង្វិចមួយឈររវោមុខទីចាត់ការសាលារៀនគួរឱ្យអាណិត ព្រោះមានកូនសិស្សជាច្រើនចោមរោម ។

- ពូ! ពូឯងចូលមករកអ្នកណា ? (ក្មេងម្នាក់សួរ)

- ពូរកលោកគ្រូ...! (ជនខ្មែរលើឆ្លើយ)

- ពូរកលោកគ្រូណា ? គាត់ឈ្មោះអី ? (សិស្សធំម្នាក់ទៀតរត់ចូល មកសួរ)

-បាទ ! បាទ ! ខ្ញុំរក...រកលោកគ្រូ សុ...សុខុម (កាលបើឃើញគេ មកចោមរោមច្រើនពេក ជនខ្មែរលើនេះភ័យរកឆ្លើយស្ទើរពុំរួច)

- លោកគ្រូសុខុម ! លោកគ្រូ...សុ...សុខុម....នៅ...មិនទាន់បាន ឆ្លើយប្រាប់ដំណឹងដល់ជនខ្មែរលើនេះផង ជួងនៃសាលារៀនក៏បន្លឺឡើង ក្មេងទាំងអស់ក៏រត់តម្រង់ទៅថ្នាក់រៀង១ខ្លួន ទុកឱ្យយុវជនខ្មែរលើយើងនៅម្នាក់ឯង ។

ក្រោយមកបន្តិច ទើបមានលោកគ្រូម្នាក់ ដើរមកជិត ហើយសួរថា :

- ឯងមករកអ្នកណា ?

- បាទ ! ខ្ញុំបាទជំរាបសួរ? ខ្ញុំបាទមករកលោកគ្រូសុខុម..!

- លោកគ្រូសុខុម ! ម៉េចបានជាឯងស្គាល់ លោកគ្រូ សុខុម ?

-បាទលោកគ្រូ ! ខ្ញុំបាទស្គាល់គាត់ កាលគាត់នៅបង្រៀនភូមិខ្ញុំបាទ ។

-ឯងមានបានរៀនសូត្រដែរ? (លោកគ្រូនេះសួរបញ្ជាក់)

- បាទ ! ខ្ញុំបាទឥតបានរៀនអក្សរ តែខ្ញុំបាទបានរៀននិយាយជាមួយគាត់ (ជនខ្មែរលើឆ្លើយយ៉ាងសុភាព ពុំសមជាមនុស្សស្បៀកពាក់ដូច្នេះទេ)

- ឯងរកគាត់មានការអ្វី? ឯងចេះនិយាយច្បាស់ល្អណាស់

-បាទ! ខ្ញុំបាទមានការចង់ជួប តើគាត់នៅបង្រៀនសាលានេះមែនទេ ?

- ចាំខ្ញុំឱ្យក្មេងទៅអញ្ជើញគាត់មក ឯងនៅត្រង់នេះសិនហើយណ្ហទេ ?

- បាទ !

មួយស្របក់ក្រោយមក លោកគ្រូសុខុមក៏បានមកដល់ :

-ខ្ញុំបាទ ! ជំរាបសួរលោកគ្រូ (យុវជនខ្មែរលើនេះសំដែងការគួរសម)

- អើ ! ឯងមករកនរណា ? (លោកគ្រូសុខុមសួរបញ្ជាក់ ព្រោះមិន ស្គាល់)

- បាទ ! ខ្ញុំបាទមករកលោកគ្រូ

- ឯងមករកខ្ញុំ ! តើឯងនៅភូមិណា ?

- បាទ ! ខ្ញុំបាទនៅភូមិពូក្រិកក្រោម លោកគ្រូភ្លេចខ្ញុំបាទហើយ ។ ខ្ញុំបាទកូនមេភូមិប្រុសនោះ ។

- ឱ! ឯងនៅភូមិពូក្រិកក្រោម ខ្ញុំដូចជាភ្លេចឯងហើយ តើឯងមករក ខ្ញុំមានការអ្វី ?

- បាទ ! ខ្ញុំបាទមកសុំនៅជាមួយលោកគ្រូ ។

-ឯងចង់នៅជាមួយខ្ញុំ ! ឯងនៅយូរឬនៅគ្រាន់តែរកទិញឥវ៉ាន់បាន ឯងត្រឡប់ទៅវិញ ?

-បាទ ! ខ្ញុំបាទមកនៅយូរ ព្រោះខ្ញុំបាទចង់នៅក្រុងនឹងគេ

-ដូច្នេះស្រួលហើយ ឯងចាំអញត្រង់នេះសិន អញទៅសុំច្បាប់លោក ចាងហ្វាងនាំឯងទៅផ្ទះ ។

ល្ងាចនេះក្រោយដែលបរិភោគរួច គ្រួសារលោកគ្រូសុខុម បានមនុស្សម្នាក់ទៀតមករស់នៅបំរើ តែមនុស្សថ្មីនេះ កូនតូចៗលោកគ្រូយើងមិនចូលចិត្តទេ ព្រោះវាខ្លាច ។ កាលណាឃើញមុខ វាចេះតែយំ ។ យប់យូរបន្តិចទៅហើយ តែពន្លឺភ្លើងអគ្គិសនីក្នុងផ្ទះ លោកគ្រូសុខុមមិនទាន់រលត់នៅឡើយ :

- ឯងឈ្មោះអី? (ប្រពន្ធលោកគ្រូសុខុមសួរ)

- បាទ ! ខ្ញុំបាទឈ្មោះប្រិក !

- ឈ្មោះប្រិក ! ហើយអាយុប៉ុន្មាន ?

- ខ្ញុំបាទអាយុ ១៨ឆ្នាំហើយ ។

- ឯងមានបងប្អូនប៉ុន្មាននាក់ .

- បាទ ៤នាក់ តែស្លាប់អស់ ២នាក់ទៅហើយ ។

- ឯងមកនេះមានប្រាថ្នាអ្វី ? ឬក៏ចង់មកលេងទេ ?

- ខ្ញុំបាទមកនេះ គឺចង់មករកប្រពន្ធខ្ញុំបាទ ។

- ប្រិកឯងមានប្រពន្ធហើយ ?

-ខ្ញុំបាទ ! មិនទាន់ការទេ តែម្ដាយខ្ញុំឪពុកខ្ញុំបាទប្រាប់ថា ប្រពន្ធដែល គាត់ស្ដីដណ្ដឹងឱ្យខ្ញុំបាទតាំងពីតូច។ម្ល៉េះ ឥឡូវមកនៅរៀនក្រុងនេះឈ្មោះមី គ្រុត ។ ខ្ញុំបាទមកនេះមានប្រាថ្នាចង់មកតាមវាយកទៅស្រុកវិញ ដើម្បីរៀបការនឹងគ្នាឱ្យហើយ ព្រោះកាលដែលវារៀននៅសាលារៀនឯភូមិខ្ញុំបាទអស់ថ្នាក់ទៅលោកគ្រូបញ្ជូនវាឱ្យមករៀននៅឯក្រុងក្រចេះ ខ្ញុំបាទថាមិនព្រមឱ្យវាមកដែរ តែម៉ែវាថា វានៅតូចឱ្យវាទៅចុះ ដល់វាធំចាំហៅមកវិញ ឥឡូវបីឆ្នាំ ហើយខ្ញុំឥតដែលឃើញវាទៅស្រុកសោះ មិនដឹងថាវាធំប៉ុណ្ណាទៅហើយទេ ។ មីគ្រុតអាយុប្អូនខ្ញុំ ៤ឆ្នាំ បើនៅឯភូមិខ្ញុំ គេត្រូវរៀបការឆ្នាំនេះហើយ ។

ទាំងអស់គ្នាអង្គុយស្ដាប់ប្រិកនិយាយ យ៉ាងស្ងប់ស្ងៀម លុះពុំឃើញ បន្តរឿងវាទៀត ទើបលោកគ្រូសុខុមសួរវាទៀតថា :

- ចុះឯងដឹងថាមីគ្រុតឯងនោះ នៅឯណាទេ ?

- បាទ ! លោកគ្រូខ្ញុំបាទឥតស្គាល់ទេ ( ប្រិកនិយាយយ៉ាងស្រងូត ស្រងាត់)

- ដូច្នេះឯងមកនៅនឹងអញ គ្រាន់តែដើររកមីគ្រុតនោះទេឬ ?

- បាទលោកគ្រូ ! ខ្ញុំបាទនៅបំរើលោកគ្រូ រួចពេលទំនេរ ខ្ញុំបាទសុំ លោកគ្រូដើររកវា ។

- ចុះបើជួបវា វាមិនព្រមត្រឡប់ទៅវិញ ឯងធ្វើយ៉ាងម៉េចទៅប្រិក ! ( ប្រពន្ធលោកគ្រូសុខុមសួរបញ្ជាក់)

- បាទអ្នក ! កាលណាខ្ញុំបាទបានជួបវា វាមុខជាព្រមទៅជាមិនខាន ព្រោះវាបានទទួលខ្សែកពីឪពុកខ្ញុំ តាមឪពុកវារួចហើយ។ គេបានហៅបងប្អូនស៊ី ផឹក កាប់ក្របីថ្វាយអ្នកតាអស់មួយក្បាលទៅហើយ វាមុខតែទៅមិនខានឱ្យតែ វាបានជួបខ្ញុំបាទ ខ្ញុំបាទនឹងនិយាយពន្យល់វា ។

- ឯងមកនេះមានប្រាប់ម៉ែឪឯងឬទេ ? ( លោកគ្រូសុខុម បញ្ជាក់)

- បាទលោកគ្រូ ! មុននឹងចេញដំណើរនេះ ឪពុកខ្ញុំបាទប្រាប់ខ្ញុំឱ្យ មករកលោកគ្រូ ហើយឪពុកម្ដាយមីគ្រុត ក៏បានជូនខ្ញុំបាទមកដល់ជើងភ្នំដែរ ។ ទាំងអស់គ្នាបានប្រាប់ខ្ញុំបាទថា ឱ្យមីគ្រុតទៅភូមិវិញជាមួយខ្ញុំបាទ ហើយរៀបការ ។ ម្យ៉ាងទៀតឪពុកខ្ញុំបាទថា សូមពឹងលោកគ្រូឱ្យជួយសួររកមីគ្រុត ។ គាត់ថា ទាល់តែលោកគ្រូជួយរកទើបរកឃើញ ។

- អើ ! មិនអីទេ ចាំអញជួយស៊ើបសួរឱ្យ តែឯងត្រូវនៅបំរើអញឬទេ កុំទៅណាផ្ដេសផ្ដាស ។

- បាទលោកគ្រូ ! ខ្ញុំបាទមកនេះ ឥតស្គាល់អ្នកណាដទៃទៀតក្រៅពី លោកគ្រូទេ សូមលោកគ្រូមេត្តារកមីគ្រុតឱ្យខ្ញុំបាទផងរកវាឃើញថ្ងៃណា ខ្ញុំ បាទសូមលោកគ្រូទៅថ្ងៃនោះ ដល់ខ្ញុំបាទការនឹងគ្នារួចខ្ញុំបាទត្រឡប់មកនៅបំរើ លោកគ្រូនឹងអ្នកវិញ ទាំងពីរនាក់ប្ដីប្រពន្ធ ។

- ដូច្នេះ ចាប់ពីស្អែកនេះទៅ ឯងស្លៀកខោខ្លីនេះទៅ ត្រចៀកឯង ឯងឈប់ពាក់ត្រសាល់ទៀតទៅ កុំឱ្យកូនគ្នាវាខ្លាចឯង ។ ព្រលឹមឡើងជួយធ្វើ ការគេ ឃើញគេធ្វើអ្វីឯងជួយគេទៅ ដូចជាពុសឧស បោចស្មៅតាមជើងរបង ឱ្យស្អាតឱ្យអញ ឯមីគ្រុតឯងនោះ ឯងកុំព្រួយចាំអញជួយរកឱ្យទាល់តែឃើញ ព្រោះវាគ្មានទៅណាទេ ឱ្យតែប្រាកដមករៀននៅក្រចេះនេះ ។

- បាទលោកគ្រូ ! ខ្ញុំបាទទទួលធ្វើទាំងអស់ ឯមីគ្រុតវាពិតជាមកផ្សារនេះហើយ កាលវាមកនៅតូច ឥឡូវប្រហែលធំហើយលោកគ្រូ

- អើ ! ពីដើមវាតូចមែន តែឥឡូវវាមុខតែធំជាងពីដើមហើយ ឯង មិនបាច់សង្ស័យទេ ។

យប់នេះ យុវជនខ្មែរលើយើងទទួលទានដំណេកមិនលក់ទេ គេសប្បាយចិត្តណាស់ ដោយបានរកលោកគ្រូសុខុមឃើញ ហើយលោកគ្រូនេះ មានចិត្តមេត្តា ឱ្យគេបានសំណាក់អាស្រ័យទៀតផង គេសង្ឃឹមយ៉ាងច្បាស់ថា មុខតែបាននាំមីគ្រុតទៅភូមិវិញជាមិនខាន ។ មួយយប់ទល់ភ្លឺប្រិកមិនដេកទេ គេអង្គុយមុខផ្ទះកណ្ដាលវាលហាលសន្សើមឥតពាក់អាវធ្វើព្រងើយ ទោះលោកគ្រូ សុខុមដេញវាឱ្យទៅដេកយ៉ាងណាក៏ដោយ ។

យើងពុំអាចសន្និដ្ឋានដល់ជំរៅចិត្តប្រិកឡើយ ដែលសុខចិត្តចោលភូមិ ជាទីស្រឡាញ់ ចោលឪពុកម្ដាយ-ប្អូនជាទីស្នេហាមកតាមរកសង្សារជាទីរលឹក ឯណោះវិញនោះ ព្រោះថាមនុស្សសត្វលោក មិនថារូបណាជារូបណា ស៊ូប្ដូរ ស្លាប់រស់ជាមួយសង្សារបណ្ដូល ចិត្តគ្រប់។គ្នា លើកលែងតែព្រះសង្ឃដែលបាន កាត់កាល កាមកិលេសដាច់ស្រឡះនោះចេញ ។

ពុទ្ធោ ! ប្រិកក៏មានចិត្តដូចមនុស្សនានាដែរ ។ ប្រិកក៏ជាមនុស្សមាន ពូជជាមួយយើងរាល់គ្នា ប្រិកក៏មានស្នេហាដូចយើងគ្រប់គ្នាដែរ ពិតមែនតែ ប្រិកកើតនៅជើងភ្នំរស់នៅឆ្ងាយពីក្រុង ខ្វះខាតការស៊ីវិល័យ ការសិក្សារៀន សូត្រ តែប្រិកចេះមានស្នេហាដែរ ។ គិតឱ្យច្បាស់ទៅទៀត ប្រិកជាមនុស្សមានពូជអម្បូរណ៍ជាអ្នកសាងអង្គរ ដូច្នេះប្រិកធ្លាប់មានខ្សែស្រឡាយជាខ្មែរផ្សាយ កិត្តិសព្ទទុកជាកេរ្តិ៍ដំណែល ឱ្យយើងរាល់គ្នា គួរយើងគិតឱ្យដិតដល់ ពិតមែនតែ គ្នាមានការរស់នៅដូចជាសត្វ តែពូជល្អ ពូជខ្ពង់ខ្ពស់ ពូជខ្មែរបូរាណកាល បើបានទឹកត្រជាក់បាចទៅលើគ្នា គ្នាមុខតែបានលូតលាស់ល្អដូចគេដូចឯងដែរ ដូច្នេះ ហើយទើបព្រះបិតាជាតិ ព្រះអង្គទ្រង់ឈ្វេងយល់អាណិតដល់ជនជំពូកនេះ ទើបព្រះអង្គប្រមែប្រមូលបញ្ជូនគ្រូផ្សព្វផ្សាយចំណេះវិជ្ជាដល់កូនចៅជនទាំងនេះ បានសិក្សចេះដឹងស្គាល់ទីក្រុងនឹងគេ ដូចប្រិកដើររកសង្សារគេនេះជាភស្តុតាងស្រាប់ ។

# ២

# ស៊ូស្លាប់ប្រសើរជាង

បីថ្ងៃកន្លងមក ប្រិកនៅបំរើលោកគ្រូសុខុមយ៉ាងស្មោះត្រង់ ។ មួយថ្ងៃៗប្រិកឥតហ៊ានទៅណាទេ ខ្លាចវង្វេងរកផ្ទះ លោកគ្រូមិនឃើញ ។ កាលណា ទំនេរឥតការអ្វីធ្វើ ប្រិកអង្គុយមាត់ទ្វាររបងផ្ទះ សំឡឹងទៅក្រៅរបងគយគន់ មនុស្សដើរតាមថ្នល់ ក្រែងជួនជាបានឃើញមីគ្រុគដើរទៅរៀន ។

ប្រិកអង្គុយនឹកមុខមីគ្រុគមិនស្គាល់សោះ ព្រោះបែកគ្នាយូរមកហើយ មិនដឹងមីគ្រុគធំប៉ុណ្ណា ស្អាតដូចម្ដេច ការសង្ឃឹមថារកមីគ្រុគឃើញនោះ ប្រិកអស់សង្ឃឹមបន្តិចម្តងៗទៅវិញហើយ ព្រោះកាលណាលោកគ្រូសុខុមត្រឡប់មក ពីធ្វើការវិញ ប្រិកតែងតែសួរថា លោកគ្រូបានជួបមីគ្រុគដែរឬទេ ? កាលបើឮ លោកគ្រូ ឆ្លើយថា នៅទេប្រិកអើយសួររកមិនលេចសោះ ។ ប្រិកដាក់ទឹកមុខ អង្គុយសញ្ជឹងសញ្ជប់ បាយមិនបាយ ទឹកមិនទឹក ។ ឃើញដូច្នេះប្រពន្ធ លោកគ្រូសុខុម រមែងមានចិត្តមេត្តាដល់ប្រិកជាទីបំផុត ។

- ប៉ាវាឯង ម្ដេចមិនសួរក្មេងទាំងអស់ដែលមកពីមណ្ឌលគីរី ថាតើ មី ណាមួយឈ្មោះមីគ្រុគនោះ ឱ្យច្បាស់ទៅមើល (ប្រពន្ធលោកគ្រូសុខុមបញ្ជាក់ ក្ដី) ។

- ឯងអើយ ! គ្នាសួរគ្រប់អស់ហើយ វាគ្មានក្មេងណាវាទទួលស្គាល់ ឈ្មោះមីគ្រុគ ដូចអាប្រិកវាថាសោះ សួរណាស់ជាណាស់ទៅលោកគ្រូខ្លះថាគ្នា ប្រហែលឆ្កួតដូចអាប្រិកដែរហើយហ្នឹង ។ គ្នាដូចជាអស់ចំណេះហើយ ក្មេងមានប៉ុន្មាននាក់ណាស់ ដែលជាកូនអ្នកខ្មែរលើមកនៅរៀនសាលាក្រចេះយើងនេះ តែគ្នាសួរវាគ្រប់គ្នាទៅ គ្មានក្មេងណាស្គាល់ឈ្មោះមីគ្រុគសោះ។ មើលចុះមី ណាមួយឈ្មោះមីគ្រុគឯងនោះ ។

- ដូច្នេះឯងគិតយ៉ាងម៉េចទៀត ឯងមើលអាប្រិកវាបាយមិនបាយ ទឹកមិនទឹក អង្គុយភ្លឹកមួយកន្លែង ហៅបីបួនម៉ាត់មិនចង់ឮផង ។

- ប្រិក ! ប្រិកឯងមកណេះ (លោកគ្រូសុខុមហៅ)

- បាទ ! ប្រិកស្ទុះរត់ចូលមកជិតលោកគ្រូសុខុម

- ឯងកុំព្រួយអីច្រើនពេកឮទេ ឯងរកបាយទឹកទៅ ឯងមកមិនទាន់ បានមួយខែផង ភ័យខ្លាចរកមិនឃើញទៅហើយអញធានារកទាល់តែឃើញ ឯងកុំព្រួយ ទុកចិត្តលើអញចុះ ។

- បាទលោកគ្រូ ! ខ្ញុំបាទព្រួយចិត្តណាស់ បើរកមីគ្រុគមិនឃើញ ខ្ញុំ បាទមិនទៅភូមិវិញទេ ព្រោះខ្មាសបងប្អូនពួកម៉ាក ។ គេមុខតែថាមីគ្រុគមិន ស្រឡាញ់ខ្ញុំបាទ ទើបវារត់ចោលខ្ញុំបាទដូច្នេះ

- មិនអីទេ ចាំថ្ងៃអាទិត្យនេះ អញហៅក្មេងប្រុស ស្រី ដែលជាខ្មែរ លើដូចឯងមកស៊ីបាយផ្ទះអញទាំងអស់គ្នា ហើយចាំមើលចុះ មីណាមួយឈ្មោះ មីគ្រុគឯងនោះ ។

ប្រិកឮដូច្នេះអរណាស់ លុតជង្គង់ក្រាបសំពះលោកគ្រូ សុខុមជាច្រើន ដង សំដែងការអំណរគុណ ។

- ឯងអរទេប្រិក បើលោកគ្រូឯងគេធ្វើដូច្នេះ ! ( ប្រពន្ធ លោកគ្រូ សុខុមសួរ)

- បាទអ្នក ! ខ្ញុំបាទត្រេកអរណាស់ ( និយាយមិនទាន់ផុត បីមាត់ផង ប្រិកដាក់ទឹកមុខស្ងួតទៅវិញ)

- ហេតុអ្វីក៏ឯងធ្វើមុខដូច្នេះប្រិក ? ( ប្រពន្ធលោកគ្រូ សុខុមសួរ បញ្ជាក់)

- ប្រិកឮដូច្នេះ ស្ទុះទៅថ្វាយបង្គំលោកគ្រូសុខុមម្តងទៀត សម្តែង អំណរគុណ ។

- បាទអ្នក ! ខ្ញុំបាទភ្លេចមុខមីគ្រុគអស់ទៅហើយ មិនដឹងជាធំប៉ុណ្ណា មុខមាត់វាដូចម្តេចទៅហើយទេ ?

- ឯងឥតចំណាំវាត្រង់ណាទេ

- បាទអ្នក ! តាមខ្ញុំបាទចាំវាស្លូតណាស់ បើវានិយាយថ្លាស់វាខូចទាំង សងខាង តែឥឡូវនេះមិនដឹងជាវាប្តូរផ្លាស់ ដូចម្តេចទៅវិញទៅហើយទេ ( ប្រិក និយាយទាំងស្រងូតស្រងាត់) ។

- ពិបាកដែរបើឯងមិនស្គាល់វាឱ្យច្បាស់ដូច្នេះ ចុះវាស្គាល់ប្រិកឯង ឬទេ ?

- បាទអ្នក ! វាស្គាល់ខ្ញុំច្បាស់ ហើយវាស្រឡាញ់ខ្ញុំទៀតផង វាចូល ចិត្តដើរតាមខ្ញុំទៅព្រៃចាប់សត្វណាស់ កាលវានៅរៀនឯណោះ តែឥឡូវនេះដឹង ជាវាភ្លេចខ្ញុំបាទទៅហើយទេក៏មិនដឹង ?

- អញពិបាកដែរប្រិក ឯងនាំឱ្យអញពិបាកសម្បើម បើឯងមិនស្គាល់ មីគ្រុគឯងនោះទេ ម្តេចក៏ឯងហ៊ានមកតាមគេ ម្តេចមិនឱ្យឪពុកវាមកតាមកូន គេទៅវាស្រួលជាង ( លោកគ្រូសុខុម មួម៉ៅ) ។

- បាទលោកគ្រូ ! ដំបូងខ្ញុំថាដូច្នេះដែរ តែឪពុកវាថា ប្រពន្ធអាណា អាហ្នឹងមិនចេះទៅតាមអត់ទៅ អញគ្មានស្គាល់ផ្លូវទៀតក្រុងក្រចេះទេ ហើយគ្មានកម្លាំងដើរមកទៀតផង ។ បើគេថាដូច្នេះ តើឱ្យខ្ញុំបាទគិតដូចម្តេចទៅ មាន តែមកខ្លួនឯង ។

- អើ ! បើអញ្ចឹងថ្ងៃអាទិត្យនេះ ចាំមើលគេឱ្យច្បាស់ទៅ បើប្រាកដ មួយណាហើយប្រាប់អញ អញជួយនិយាយឱ្យវាទៅតាមឯងកុំឱ្យឯងឆ្អួតចិត្ត ទៀត ។

ប្រិកឮដូច្នេះ ស្ទុះទៅថ្វាយបង្គំលោកគ្រូសុខុមម្តងទៀត សំដែងអំណរ គុណ ។

ពិតមែនតែប្រិកមានកំណើតជាជនខ្មែរលើ តែប្រិកបានចេះដឹងខ្លះនៃ ច្បាប់សុភាវធម៌ ។ ប្រិកចេះគោរពបំរើលោកគ្រូសុខុមទាំងប្តីប្រពន្ធ លុះត្រាតែលោកគ្រូយើងស៊ូជួយស៊ើបសួររក មីគ្រុគឱ្យប្រិករហូតដល់ខាតបង់ទ្រព្យធនខ្លះ ក៏លោកគ្រូយើងមិនគិត ។ ខ្ញុំសូមបញ្ជាក់ថា សិស្សានុសិស្សដែលមកពីលើសុទ្ធ សឹងតែបានអាហាររូបករណ៍សំណាក់នៅសាលាទាំងអស់គ្នា ។

ព្រឹកថ្ងៃនេះ ប្រិកខំរែកទឹកដាក់ពាងពេញអស់គ្មានសល់ ព្រោះជាថ្ងៃ ដែលប្រិកត្រូវបានជួបមីគ្រុគបណ្តូលចិត្តគេ ហើយបើយ៉ាងហោចណាស់ ប្រិក បានជួបកូនចៅអ្នកខ្មែរលើដូចគ្នាដែរ ។ ផ្ទះលោកគ្រូសុខុមមានអ្នកគ្រូ-លោក គ្រូ មិត្តអ្នករាជការដទៃទៀតជាច្រើន មកជួបជុំទទួលភោជនាហារ សប្បាយលេងរូបរួមជាមួយកញ្ញា នឹងកម្លោះកូនអ្នកខ្មែរលើជាច្រើនរូបយ៉ាងសប្បាយរីករាយ តែភ្ញៀវទាំងអស់ឥតបានដឹងបំណងលោកគ្រូសុខុមឡើយ ឯប្រិកវិញ គេឥតបរិភោគអ្វីទេ គេអង្គុយសំឡឹងមុខនារីមួយរូបក្នុងចំណោមនារីជាច្រើនរូបទៀត ដែលបានមករួមក្នុងពិធីនេះដែរ តែប្រិកពុំច្បាស់ថាមួយណាជាមីគ្រុគ របស់គេសោះ ។ ប្រិកចេះតែគិតក្នុងចិត្តថា បើនាងនោះជាមីគ្រុគមែនច្បាស់ជាមីគ្រុគមកឱបគេមិនខាន ។

លុះយូរបន្តិចទៅ លោកគ្រូសុខុមឃើញប្រិកនៅស្ងៀម ហាក់ដូចមិន ច្បាស់មួយណាសោះនោះ លោកគ្រូយើងក្រោកឈរឡើង ហើយមានវាចាថា :

ខ្ញុំបាទសូមអភ័យទោសពីសំណាក់អស់លោកជាមិត្ត ដើម្បីសូមសួរ នាងៗដែលមានកំណើតជាខ្មែរលើ ។

ទាំងអស់គ្នាស្ងាត់ឈឹង ចាំស្តាប់លោកគ្រូសុខុម ។

- តើមាននាងណាស្គាល់ប្រិកនេះទេ ប្រិកនេះជាជនខ្មែរលើដែរ ហើយបានសុំនៅជាមួយខ្ញុំ ខ្ញុំសូមបញ្ជាក់ប្រិកពិតជាមាន កំណើតជាខ្មែរលើមែន តែប្រិកជាមនុស្សចេះដឹងល្អណាស់។ និយាយចប់ លោកគ្រូសុខុម ស្ទុះទៅលើកប្រិកឱ្យក្រោកឈរឡើង ។

ប្រិកលើកដៃសំពះភ្ញៀវទាំងអស់សំដែងការគួរសម ។

ឥតមានអ្នកណាម្នាក់ទទួលស្គាល់ប្រិកឡើយ ទាំងអស់គ្នាស្ងាត់ឈឹង ។

មួយស្របក់ក្រោយមក សភាពនៃនារីមួយរូបបានងើបពីចំណោមនារី ទាំងឡាយ ហើយពោលទាំងញញឹមស្រស់ថា :

- គាត់មកពីភូមិណា ? ហើយមានឈ្មោះអ្វី ?

គ្រាន់តែឃើញសភាពនារីនេះភ្លាម ប្រិកស្ទុះស្ទៀវទៅរកគេ ហើយ ស្រែកហៅភ្លាត់សំលេងថា :

- មីគ្រុគ ! មីគ្រុគឯងមិនស្គាល់អញទេ ? អញមករកឯងណា !

- ទេ ! ទេ ! ខ្ញុំមិនមែនឈ្មោះមីគ្រុគណាទេ ! ពូច្រឡំហើយ ខ្ញុំគ្រាន់ តែចង់ជំរាបសួរពូថា តើពូនៅភូមិណា ? ពូឯង ឈ្មោះអ្វី ?

ឮថាដូច្នេះ ប្រិកថយក្រោយក្រាបហើយពោលថា :

- ខ្ញុំឈ្មោះប្រិក នៅភូមិពូក្រិកក្រោម មកតាមរកមីគ្រុគ ជាគូដណ្តឹង របស់ខ្ញុំ តើមាននាងណាស្គាល់ទេ ?

- នៅភូមិពូក្រិកក្រោម ឈ្មោះប្រិក ខ្ញុំឥតស្គាល់ទេ ។ ភ្ញៀវទាំងអស់មានការងឿងឆ្ងល់គ្រប់ៗគ្នា ព្រោះឃើញប្រិកគួរ ឱ្យចង់សើចកាល បើគេឆ្លើយថាមិនមែនគេនោះ ឈ្មោះមីគ្រុគទេ ក៏ថយទៅអង្គុយស្ងៀមធ្វើស្ងួញ ស្ងួចសត្វស្វាត្រូវក្បាលមួយព្រនង់

ប្រពន្ធលោកគ្រូសុខុម ស្ទុះទៅជិតនាងនោះម្តងទៀត ហើយខ្សិបខ្សៀប សួរថា :

- តើនាងឬ ពិតជាឈ្មោះមីគ្រុគនោះ ?

- ចាំៈ អ្នកមីង ! មិនមែននាងខ្ញុំទេ ? នាងខ្ញុំកាលនៅភូមិឈ្មោះ ម្រុះ ទេ ហើយនាងខ្ញុំនៅឆ្ងាយពីភូមិពូក្រិកក្រោមនេះឆ្ងាយណាស់ ។

- តើនាងមានស្គាល់កូនស្រីណាទេ ដែលឈ្មោះគ្រុគនោះ? មីងអាណិត ប្រិកណាស់ គ្នាមកតាមរកមីគ្រុគនេះប៉ុន្មានថ្ងៃហើយ ឥតបាយ ឥតទឹកទេ ។

- ចាំៈ អ្នកមីង ! ក្នុងចំណោមគ្នាខ្ញុំនេះ ដូចជាគ្មានអ្នកណាឈ្មោះគ្រុគ ទេ ! មានតែសុភាព គេមានកំណើតនៅភូមិពូក្រិកក្រោមដែរ (នាងចង្អុលទៅ មិត្តនារីម្នាក់ទៀត ដែលអង្គុយស្ងៀមមានទឹកមុខស្ងួត) ។

- ចាំៈ អ្នកមីង ! នាងខ្ញុំនៅភូមិពូក្រិកក្រោមមែន តែនាងខ្ញុំឥតបាន ស្គាល់គាត់ទេ ។

អស់សង្ឃឹមគ្មានអ្នកណាស្គាល់ប្រិកទាល់តែសោះ ឯប្រិកវិញក៏គ្មាន ស្គាល់នាងណាមួយឈ្មោះមីគ្រុគដែរទេ. ការជប់លៀងពេល នេះបាន ចប់សព្វគ្រប់ ក្រោយដែលភ្ញៀវទាំងអស់លាត្រឡប់ទៅផ្ទះវិញ ។

ក្មេងៗទាំងអស់ឥតទាន់ត្រឡប់ទៅសាលាវិញទេ គេនៅជួយលាងចាន ឆ្នាំង រួចសព្វគ្រប់ទើបគេត្រឡប់ទៅសាលាវិញ ។

ឯចំណែកប្រិកវិញ គ្នាខំបញ្ចូលខ្លួនទៅក្នុងចំណោមក្មេងៗទាំងអស់នេះដែរ ដើម្បីគយគន់រកមើលក្រែងលោបាន ឃើញមីគ្រុគបណ្តូល ចិត្តគេ ។ តែឥតប្រយោជន៏សោះ ប្រិកមិនស្គាល់នាងណាមួយ ដែលឈ្មោះគ្រុគសោះទេ ប្រិកអស់សង្ឃឹមត្រឡប់ទៅអង្គុយដកដង្ហើមធំម្នាក់ឯង លុះក្មេងៗទាំងអស់នោះត្រឡប់ទៅផ្ទះវិញ គេក៏នាំគ្នាមកលាប្រិកគ្រប់ៗគ្នាដែរ ប្រិកខំពោលផ្តាំតាមក្មេងៗទាំង អស់ថា :

សូមនាងទាំងអស់គ្នា មេត្តាជួយសួររកមីគ្រុគឱ្យខ្ញុំផង ។ បើបានជួបវា ប្រាប់វាថា ប្តីមកតាមយកវាទៅផ្ទះរៀបការ កុំឱ្យព្រាយខ្មោច បិសាចធ្វើទាន់ ។ សូមនាងទាំងអស់ប្រាប់វាថា ខ្ញុំនៅចាំផ្ទះលោកគ្រូនេះទាល់តែបានជួបវាទើបត្រឡប់ទៅផ្ទះវិញ ។ ប្រិកឥតមានសង្ឃឹមថា បាន ជួប មីគ្រុគនោះទៀតទេ តែ ប្រិកចេះតែផ្តាំៗទៅ ក្រែងលោគេជួយរកឃើញ ។

# ៣

## អភ័ព្វអ្វីតែខ្ញុំ

បីខែកន្លងទៅយ៉ាងរហ័សក្រៃលែង ប្រិកក៏ពុំទាន់ត្រឡប់ទៅស្រុកភូមិ កំណើតវិញដែរ ព្រោះគេបានសម្រេចចិត្តថា កាលណារកមីគ្រុគគេឃើញ ទើបគេត្រឡប់ទៅភូមិកំណើតប្រកបមុខរបរដូចប្រក្រតីទៀត បើរកមិនឃើញទេ គេស៊ូនៅធ្វើខ្ញុំបំរើលោក គ្រូសុខុមរហូតដល់អស់សង្ខា ។

ឯលោកគ្រូសុខុមវិញ លែងជឿប្រិកទៀតហើយ ព្រោះគេជំនុំគ្នាប្តី ប្រពន្ធយល់ឃើញថា ប្រិកយកលេសនេះមកប្រើ ដើម្បីឱ្យគេអាណិតវាឱ្យវានៅ ជ្រកកោនផងប៉ុណ្ណោះ ម្ល៉ោះហើយគេឈប់ជួយរកមីគ្រុគឱ្យប្រិកទៀតហើយ ។

រាល់ថ្ងៃប្រិកនៅតែមានសង្ឃឹមខ្លះថា មីគ្រុគគេនិងមករកគេជាមិនខាន ។ ឥឡូវនេះប្រិកនិយាយប្រាប់គេពីរឿង មីគ្រុគណានោះទៀត គេលែងជឿលែងយកចិត្តទុកដាក់ស្តាប់ប្រិកទៀតហើយ ។ ពីដើមគេអាណិតប្រិក ឥឡូវប្រិកអស់ឥទ្ធិពលអង្វរគេ ឱ្យជួយរកមីគ្រុគទៀត ព្រោះលោកគ្រូសុខុម ជឿជាក់ថាសិស្សានុសិស្សខ្មែរលើ ដែលមករៀននៅក្រុងក្រចេះ ហើយមានអាហារូបករណ៍នោះតែប៉ុណ្ណឹងគ្នា បើអស់ប៉ុណ្ណឹងហើយ គ្មានអ្នកណាស្គាល់ប្រិកសោះ តើមីគ្រុគរបស់ប្រិកនោះនៅឯណា ? ច្បាស់ជាគ្មានរូបមីគ្រុគណាទៀតទេ ។

ថ្ងៃណាក៏ដូចជាថ្ងៃណា យប់ណាក៏ដូចជាយប់ណា ប្រិកឥតសូវបាន ដំណេក បានបាយទឹកទេ ប្រិកនឹកតែគូប្រចាំជីវិតគេ ។ ប្រិកបានប្តេជ្ញាមិន ត្រឡប់ទៅស្រុកវិញជាដាច់ខាត ដោយខ្លាចគេជេរលថា ប្រិកមនុស្សប្រពន្ធរត់ ចោលខូចឈ្មោះឪពុកម្តាយ ខូចទំនៀមទំលាប់មនុស្សស្រុកភ្នំ (ខ្មែរលើ) ។ ស៊ូ ស្លាប់ទៅវិញជាជាង រស់នៅអភ័ព្វដូច្នេះ ។

ថ្ងៃនេះ ព្រះអាទិត្យរៀបអស្តង្គតទៅហើយ លោកគ្រូ សុខុមបានទៅ ដល់ផ្ទះយឺតយូរបន្តិច ព្រោះគាត់មានការសំខាន់ ។ គ្រាន់តែដល់ផ្ទះភ្លាម លោក គ្រូសុខុមហៅប្រិកមកប្រាប់ថា :

- ប្រិក ! ថ្ងៃនេះខ្ញុំបានទទួលសំបុត្រអនាមិក ១ច្បាប់ ដែលខ្ញុំខំតាម សួររកម្ចាស់សំបុត្រនេះមិនឃើញសោះ ។
- សំបុត្រអនាមិក និយាយពីស្អីប៉ាវ៉ា (ប្រពន្ធលោកគ្រូ សុខុមសួរប្តី គាត់បញ្ឆោក់ជំនួសប្រិក) ។
- សំបុត្រនេះតាមសេចក្តីជារបស់មីគ្រុគ ដែលប្រិកសួររកនោះម៉ែវ៉ា, (លោកគ្រូសុខុមបញ្ជាក់) ។
- ចុះនៅឯណាសំបុត្រ ផ្ញើមកអ្នកណា ? ម្តេចឯងមិនសួរអ្នកយក សំបុត្រមកឱ្យច្បាស់ ?
- ប្រិកនៅស្ងៀមឥតនិយាយអ្វី ព្រោះវាមិនទាន់យល់ច្បាស់នូវហេតុ ការណ៍ដែលគេនិយាយគ្នានេះឡើយ ។
- ឱ្យខ្ញុំសួរអ្នកណាម៉ាក់វ៉ា ? បើកម្មករសាលាយកមកឱ្យ ប្រាប់ខ្ញុំថា ចីសុខធ្វើការនូវប៉ុស្តិ៍ខ្សែរលួសយកមកឱ្យ (លោកគ្រូសុខុមរៀបរាប់ប្រាប់ប្រពន្ធគាត់)
- មើល៍ ! ឯងមើលទៅមើហ៏ តើថាម៉េចខ្លះ ? លោកគ្រូ សុខុមលា សំបុត្រអានខ្លាំងៗឱ្យប្រិកនឹងប្រពន្ធលោកស្តាប់ :

ក្រចេះថ្ងៃ . . .

ប្រិក ! បងសម្លាញ់,

អូនស្តាយណាស់ ដោយនៅស្ងៀមមិនបានតបនិងការសួររកឈ្មោះ អូន នៅចំពោះមុខភ្ញៀវជាច្រើន ដែលលោកគ្រូសុខុម មានមេត្តារៀបចំឡើង ដើម្បីបងបានសួររកឈ្មោះអូន ។

ប្រិកបង ! ព្រហ្មលិខិតបានដៅបញ្ជាក់ថា យើងទាំងពីរនាក់ពិតជាគូ ព្រេងនឹងគ្នាជាប្រាកដ ទោះបីយ៉ាងណាក៏អូនមិនបោះបង់បងចោលដែរ ព្រោះឪពុកម្តាយយើងទាំងពីរនាក់បានផ្សំផ្គុំយើងតាមទំនៀមទំលាប់យើងជាមនុស្ស ស្រុកភ្នំរួចហើយ យើងក៏មិនត្រូវក្បត់គ្នាជាដរាបដែរ ។ តែបងអើយ ! ហេតុដែលនាំឱ្យអូនអត់ទ្រាំមិនទំលាយការពិតនេះប្រាប់អ្នកណាឬជំរាបលោកគ្រូជា ទីគោរពឱ្យជ្រាបឈ្មោះអូននឹងរឿងអូនជាមួយបង ក៏ព្រោះតែអូនចង់រៀន សូត្រឱ្យបានច្រើនជាងនេះទៅទៀត បំណាច់ចេញពីស្រុកភូមិមកហើយ អូនស្រឡាញ់បង !

អូនគោរពបង ! អូន និងបំរើបងទៅអនាគត ឱ្យសមជាប្តី ប្រពន្ធក្នុងសម័យស្រុកទេសមានការស៊ីវិល័យ ។ បងប្រិក ! បងជ្រាបទេ កាលយើងនៅឯភ្នំ យើងឥតដឹងថាស្រុកទេសយើងមានដំណើរលូតលាស់យ៉ាងណាទេ ។ បើយើងនៅតែស្រុកយើង ដូចបង្កែបក្នុងអណ្តូង ឥតមើលឃើញវែងឆ្ងាយឡើយ ។ ដូច្នេះ សូមបងអត់ទ្រាំកុំអាលចង់ស្គាល់មុខអូន អូនស្គាល់មុខបងច្បាស់ តែអូនខាំមាត់មិនទំលាយប្រាប់បង មកពីអូនស្រលាញ់ការរៀនសូត្រ ។

បង ! ចៀសវាងពេលទំនេរ បងកុំនៅស្ងៀមត្រូវទៅរៀនសូត្រនិងគេ ក្រៅពីពេលបងបំរើលោកគ្រូ បងត្រូវខំស្វាធ្យាយសិក្សាសួរលោកគ្រូត្រង់ណាបង មិនយល់មិនយូរប៉ុន្មានទេ បងនិងចេះអាន ចេះសរសេរសំបុត្រឆ្លងឆ្លើយទៅរកអូនវិញ ។ ថ្ងៃណាដែលបងចេះសរសេរចេះមើលអក្សរខ្លួនឯងថ្ងៃនោះ ហើយដែលអូនឱ្យបងស្គាល់មុខអូន ។

ប្រិកបង ! កាលណាយើងមានចំណេះវិជ្ជាគ្រប់គ្រាន់ហើយ យើងត្រូវត្រឡប់ទៅដឹកនាំបំបើកភ្នែកក្រុមគ្រួសារយើង បងប្អូនយើងញាតិជិតខាងយើង ឱ្យបានស្គាល់នូវតំលៃនៃវប្បធម៌ អារ្យធម៌-វឌ្ឍនធម៌-សុភាវធម៌ នឹងការស៊ីវិល័យនៃស្រុកទេសទៀតផង ។

បង ! ឆ្នាំនេះអូនប្រឡងចូលថ្នាក់ទី ៦ ទំនើបហើយ តែបួនឆ្នាំទៀត ប៉ុណ្ណោះ អូនអាចប្រឡងយកសញ្ញាប័ត្របានមួយសន្លឹក ដើម្បីទុកជាភស្តុតាងតទៅ ហើយអូននិងត្រឡប់ទៅភូមិយើងវិញ ដើម្បីរៀបការជាមួយបង តាមទំនៀមទំលាប់ស្រុកយើងមិនហ៊ានខានឡើយ ។ តែបងអើយ ជាពិសេសអូនសូមចិត្តបងខំរៀន ខំបំរើលោកគ្រូ ។ នៅតែ ៤ ឆ្នាំទៀតទេ យើងទាំងពីរនាក់ ក៏ពុំទាន់ហួសអាយុរៀបការនៅឡើយដែរ ។ វ័យយើងទាំងពីរនៅរៀនបាន សូម បងមេត្តាតាមបណ្តាំអូនកុំបីខានឱ្យសោះ ។

ពីអូនរបស់បង "មីគ្រុគ"

ក្រោយដែលអានសំបុត្រនេះចប់ ប្រិកលោតសឹងតែបាក់ផ្ទះ ទាល់តែ លោកគ្រូសុខុមសំឡុតថា :

- នែប្រិក ! នៅស្ងៀម ប្រយ័ត្នអញលែងមើលឱ្យស្តាប់ទៀតឮទេ ?

- បាទលោកគ្រូ ! ខ្ញុំបាទត្រេកអរណាស់ សូមលោកគ្រូមេត្តាមើលឱ្យ ខ្ញុំបាទស្តាប់ម្តងទៀត ។

- ឃើញទេ ប៉ាវ៉ា មីគ្រុគរបស់ប្រិកមានមែន ឯងចេះតែថាគ្នាភរគ្នា ភូត ឥឡូវឃើញទេ ។

- ខ្ញុំហួសចិត្តវាម្តងម៉ែវ៉ា ក្មេងស្រី១មកពីមណ្ឌលគីរីមាន តែ៨នាក់ទេ សួរកុំឱ្យមាននាងណាឆ្លើយថាស្គាល់អាប្រិក ។ ដល់មានសំបុត្រនេះទៀត ខ្ញុំខំទៅសួររក ក៏គ្មានអ្នកណាទទួលស្គាល់សោះ ។ ចុះវាពូកែលាក់ខ្លួនវាម្លេះ អញសុំចាញ់ ហើយ ។

- ប៉ាវ៉ា ! ឯងមើលប្រិកវាបិទមាត់មិនជិតទេ វាសប្បាយចិត្តណាស់ឃើញទេ ។ ខ្ញុំអាណិតប្រិកណាស់ ឯងគិតជួយរបៀបណា ? ឱ្យគ្នាជួបគ្នាទៅចុះ ជួយយកតែបុណ្យទៅ ! តាមខ្ញុំ ខ្ញុំថា មើលស្រីនោះវាមិនចោលប្រិកទេ តែវា អង្វរឱ្យប្រិកខំរៀន ឱ្យបានចេះអក្សរ ។ ថ្ងៃណាប្រិកចេះអក្សរថ្ងៃនោះហើយ ដែលវាឱ្យប្រិកស្គាល់មុខវា ។

- ចំជាពិបាកមែន ! អាក្មេងអស់នេះ វាគិតលេងល្បែងជាមួយអញ ដល់អង្គាល់ទៅនឹង ។

- ណ្ហើយប៉ាវ៉ា ! ចាំមើលមើល៍ វាទៅជាយ៉ាងម៉េចទៅទៀត ឱ្យវាដើរ អស់ក្បួនវាទៅ ។

- ប្រិកមកណេះ ! (លោកគ្រូសុខុមហៅ)

- បាទលោកគ្រូ (ប្រិកឆ្លើយយ៉ាងសុភាពហាក់ដូចអង្វរឱ្យគេអាណិត)

- ឯងចាំទេ ក្នុងសំបុត្រនេះ នាងគ្រុគឯងនោះ គេថាទាល់តែឯងចេះ មើលអក្សរខ្លួនឯងបាន ទើបគេឱ្យឯងស្គាល់មុខគេ តើឯងគិតដូចម្តេច ?

- បាទលោកគ្រូ ! ខ្ញុំបាទមិនដឹងគិតយ៉ាងម៉េចទេ ខ្ញុំបាទ ចាស់ហើយ រៀនមិនងាយចេះទេ ។

- ឯងមិនទាន់ចាស់ទេប្រិក ព្រោះឯងទើបតែអាយុ១៨ឆ្នាំ ឯងអាច រៀនបាន តែឯងខំរៀនឱ្យមែនទែន ។ ស្អែកនេះអញនាំឯងទៅរៀនជាមួយពួក អនក្ខរកម្មដែលសុទ្ធតែចាស់ រៀននៅឯវត្តឯណោះឮឬទេ ?

- បាទលោកគ្រូ ខ្ញុំបាទសូមអរគុណលោកគ្រូហើយ !

- ឯងមានសំណាងណាស់ ចេះពេលនេះត្រូវចំឱកាសដែលសម្ដេចទ្រង់ មានព្រះរាជបញ្ជាឱ្យបំបាត់អក្ខរកម្ម ហើយឯងបានទៅរៀននិងគេដោយឥតពិ បាកឡើយ ដូច្នោះមុនពេលឯង ចូលដេក ឯងត្រូវថ្វាយបង្គំព្រះបរមឆាយាល័ក្ខ ព្រះបិតាអក្សរសាស្ត្រជាតិបីដង ដើម្បីរំឭកព្រះករុណាទិគុណនៃព្រះអង្គឱ្យរាល់ ថ្ងៃណាប្រិក ។

- បាទលោកគ្រូ ! ខ្ញុំបាទនឹងគោរពតាម មិនហ៊ានខានឡើយ ។

# ៤
# នេះចំជាចិត្តកូនម៉ែ

ស្អែកឡើង..... សិស្សានុសិស្សទាំងអស់ដែលមានវាសនា បានសំណាក់ ក្នុងសាលា មិនថាតែសិស្សខ្មែរលើទេ ឯសិស្សខ្មែរកណ្ដាលក៏មានការសង្ស័យនឹង រឿងប្រិក មករកសិស្សស្រីម្នាក់ ឈ្មោះគ្រុគដែរ ជាពិសេសពួកក្រុមសិស្សនារី ដែលមានកំណើត ជាខ្មែរលើនោះចាប់អារម្មណ៍ជាងគេ ព្រោះលោកគ្រូ សុខុម តែងតែមកស៊ើបសួរមិនចេះអស់មិនចេះហើយ ពីឈ្មោះមីគ្រុគគូ ដណ្ដឹងប្រិក ។

- សុភាព ! ឯងពិតជាមិនស្គាល់ប្រិកនោះសោះឬ ? (សិស្សស្រីម្នាក់ ឈ្មោះប្រ៉ូន តែមកនៅរៀនឈ្មោះចរិយាសួរ)

- ចរិយា ! ឯងនៅតែមិនជឿខ្ញុំទៀត ខ្ញុំថាមិនស្គាល់ គឺពិតជាមិនស្គាល់ ខ្ញុំទៅលាក់ធ្វើអ្វី ?

- ក្រែងឯងមានកំណើត នៅភូមិពូក្រិកក្រោមនោះដែរ ឬទេ ?

- គ្នាកើតនៅភូមិនោះមែន តែយើងមិនស្គាល់ទាល់តែសោះពូប្រិក ?

- គ្នាអាណិតពូប្រិកណាស់ ព្រោះដូចយើងធ្លាប់ដឹងទំនៀមស្រុកយើង ស្រាប់ (ចរិយាបញ្ជាក់)

- គ្នាក៏អាណិតដែរ បើពិតជាតួសុភាពឯងប្រាកដ ប្រាប់គេឱ្យត្រង់ទៅ គេជួយអរកុំឱ្យគ្នាខូចចិត្ត (សិស្សស្រីម្នាក់ទៀត ថ្លែងមកទៀត)

- កញ្ញាឯងក៏នៅតែមិនព្រមជឿខ្ញុំទៀត (សុភាពឆ្លើយ ដោយមានទឹក មុខញញឹម១ដាក់មិត្តនារីគេម្នាក់ទៀត ឈ្មោះគ្រិន តែមករៀនឈ្មោះកញ្ញា)

- នរណាមិនសង្ស័យសុភាព ជាមីគ្រុគរបស់ពូប្រិក បើមានទឹកមុខ ស្រស់បប្រិមដូច្នោះ (ចរិយាឆ្លើយមកទៀត)

- ចរិយា ! កញ្ញានឹងមិត្តទាំងអស់ ម្ដេចក៏ចេះតែមកជជីកសួរខ្ញុំម្នាក់ ដូច្នេះ ខ្ញុំថាមិនមែនខ្លួនខ្ញុំទេ ដែលមានឈ្មោះគ្រុគនោះ ។ ឯងទាំងអស់មិន ស្គាល់ឈ្មោះកំណើតយើងទេឬអ្វី ? បានជានាំគ្នាមកចោទតែខ្ញុំម្នាក់ដូច្នេះ ។ ខ្ញុំ សង្ស័យតែសុជាតាឯណោះទេ ដែលគេនៅស្ងៀមឥតនិយាយស្ដីឥតរវល់គិតគូរ ធ្វើព្រងើយគិតតែខំទន្ទេញមេរៀន ដើម្បីប្រឡងហាក់មិនដឹងខ្លួន (សុភាព ដោះស្រាយ ព្រោះឃើញថាគេសង្ស័យលើខ្លួនខ្លាំងពេក) ។

- តើមែនទេសុជាតា ? ឥឡូវនេះគេបែរមកសង្ស័យឯងវិញហើយ (ចរិយាងាកមករកសុជាតា)

- ឯងទាំងអស់គ្នាចេះតែនាំគ្នា គិតគូររឿងឥតប្រយោជន៍ទៅ ហើយចេះតែដើរឆ្លើយដាក់គេឯង ម្ដងអ្នកនេះ ម្ដងអ្នកនោះឥតគិតថាជិតប្រឡង ហើយ មិនគិតខ្លួន តិចលោប្រឡងធ្លាក់ លោក គ្រូដេញឈប់ឱ្យរៀន (សុជាតា ឆ្លើយយ៉ាងសុភាព) ។

- ហ្នឹងវើយ ! កុំលេងគេ គេកំពុងតែខំរៀន ព្រោះគេចង់ធ្វើលោកស្រី (កញ្ញានិយាយចប់ ទាំងអស់គ្នាសើច)

- ឯងនិយាយនេះ ពិតជាមិនបានគិតទាល់តែសោះ ព្រោះនរណាដែល មិនចង់ចេះ មិនចង់ដឹង ហើយបើបានការចេះដឹងជាប្រាកដមែន នោះខ្លាចអ្វីនិង ធ្វើលោកស្រី (សុជាតាឆ្លើយ) ។

- មែន ! សុជាតានិយាយត្រូវ ! យើងគ្មានចំណេះហើយក្រទ្រព្យទៀតផងនោះ តើយើងអាចក្លាយបានជាលោកស្រីដែរ ឬទេ ? (សុភាពយល់ស្រប) ។

- ដាច់ឆ្នាំនេះសុជាតាគេពិតជាប្រឡងជាប់ហើយ ព្រោះគេខំរៀន ណាស់មែនទេ (កញ្ញាបន្ថែមមកទៀត)

- រួចចុះឯងទាំងអស់គ្នានេះ ចាំអីទៀត មិនគិតគូររកសំរាកទៅ ចាំដល់ ណាទៀត (លោកគ្រូអនិរក្សចូលមកដល់)

- ចាំៈ លោកគ្រូ ! គ្នាតែ ៨នាក់រកឈ្មោះមីគ្រុត ដែល ពូប្រិកនៅ សំណាក់ផ្ទះលោកគ្រូសុខុម ស្វែងរកមិនស្គាល់សោះ ទើបខ្ញុំទាំងអស់គ្នានេះចេះតែឆ្ងល់ (ចរិយាជំរាបទៅលោកគ្រូអនុរក្ស)

- លោកគ្រូឆ្ងល់ណាស់ដែរ តើពិតឬទេក្នុងពួកឯងទាំង ៨ នាក់នេះ មានឈ្មោះគ្រុតនោះឬទេ ?

- គ្មានទេ ! លោកគ្រូកុំឆ្ងល់ឱ្យសោះ (សុភាពឆ្លើយ)

- មានលោកគ្រូ ! ព្រោះលោកគ្រូសុខុមប្រាប់ខ្ញុំថា មានអ្នកណាម្នាក់ សរសេរសំបុត្រទៅគាត់ ប្រាប់ថាមីគ្រុតនោះ និង បង្ហាញខ្លួនគេឱ្យប្រិកស្គាល់ លុះកាលណាប្រិកនោះចេះមើល ចេះសរសេរអក្សរខ្លួនឯង ហើយដល់គេប្រឡង ឌីប្លូមជាប់ទើបគេព្រមរៀបការជាមួយប្រិក ហើយគេសន្យាទៀតថា គេមិនបោះ បង់ប្រិកចោលឡើយ (កញ្ញាបញ្ជាក់រឿងនេះជំរាបលោកគ្រូអនុរក្ស)

- ដូច្នេះឯងទាំងអស់គ្នារកឈ្មោះនេះមិនឃើញ ឬយ៉ាងណា (លោក គ្រូអនុរក្សបញ្ជាក់)

- រកមិនឃើញទេលោកគ្រូ ព្រោះទាំងអស់គ្នាសុទ្ធតែប្រកែក ពុំព្រម ទទួលឈ្មោះគ្រុតនេះ ជាឈ្មោះខ្លួនសោះ (កញ្ញា ឆ្លើយ)

- ដូច្នោះលែងគិតគូរទៀតទៅ ត្រូវនាំគ្នាគេងទៅ ហើយខំរៀនឱ្យមែនទែន កុំគិតតែប្រឡែងគ្នាជាការឥតប្រយោជន៍នោះទៀត (លោកគ្រូអនុរក្សឱ្យ ដំបូន្មាន)

- ពួកអស់នេះខូចណាស់លោកគ្រូ ១ ថ្ងៃៗ គិតតែពីរឿងគេ ឥតគិត រៀនសោះ លោកគ្រូមេត្តាដាក់ទណ្ឌកម្មវាម្តងទៅដើម្បីឱ្យវាកោត ខ្លាច (សុជាតា ប្តឹងលោកគ្រូអនុរក្ស)

- សុជាតាក៏ដូចគ្នាដែរលោកគ្រូ គិតតែនាំគ្នាជជែកហើយខ្លួនឯងនោះ ប្រហែលជាតួឯកឈ្មោះគ្រុតនោះក៏មិនដឹង (ចរិយា ឆ្លើយតប)

- ស្អីចរិយា ! ឯងថាយើងនាំឯងប្រឡែងលេង ហើយហ៊ានចោទថា យើងឈ្មោះគ្រុតនោះទៀតផង ! ប្រយ័ត្នណាំ យើងមិនចូលចិត្តទេ វើយ ! (សុជា តាខឹង)

- ណ្ហើយ ! នៅឱ្យស្ងៀមទៅកុំប្រកែកគ្នា តិចលោទាស់គ្នានាំឱ្យពិបាកដល់លោកគ្រូទៀត (លោកគ្រូអនុរក្សឃាត់)

- មែនលោកគ្រូ ! និយាយលេងច្រើននាំឱ្យឈ្លោះគ្នា ការពិតសុជាតា គ្នាឥតដែលជជែកលេងទេ គ្នាខំរៀនណាស់ តែចរិយាគ្នានិយាយលេងទេតើព្រោះ ឮសុជាតាសុំលោកគ្រូដាក់ទោសពួកខ្ញុំ (សុភាពឆ្លើយកាត់)

- នរណាគេមិនដឹង លោកស្រីជាសិស្សឧស្សាហ៍នោះ (ចរិយាឆ្លើយ មកទៀត)

- ឈប់និយាយចរិយា ប្រយ័ត្នសុជាតាខឹង ព្រោះមុខកាន់តែក្រហម ខ្លាំងហើយ កុំឱ្យកើតរឿងគ្នាឯងនោះ (កញ្ញាអង្គុយស្ងៀមតែដល់ឃើញមាន រឿងដូច្នេះក៏ឆ្លើយកាត់មកទៀត)

- ចរិយាឯងចូលចិត្តប្រឡែងលេងច្រើនណាស់ យើងនៅរៀនជាមួយ គ្នា មានអ្នកណាទាន់បានធ្វើលោកស្រី ហេតុអ្វីបានជាចូលចិត្តយកពាក្យនេះមក ប្រើ (សុជាតាឆ្លើយតបមកទៀត)

- ឯងខឹងនឹងយើងឬ សុជាតា យើងស្រឡាញ់រាប់អានឯងទើបយើង និយាយលេង (ចរិយាឆ្លើយ)

- យើងមិនមែនខឹងទេ តែយើងគ្រាន់តែមិនចូលចិត្ត ដូចឯងធ្លាប់ដឹង ចិត្តយើងស្រាប់ (សុជាតាឆ្លើយតប)

- ឈប់ជជែកគ្នាទៅ ចរិយាទៅកន្លែងឯងទៅ។ កញ្ញាសុភាពក៏ដូច គ្នាដែរ ទៅៗកុំមករំខានសុជាតាអាណិតគ្នា គ្នាស្លូតណាស់កុំធ្វើបាបគ្នា ( លោកគ្រូអនុរក្សឃាត់ហើយក៏ដើរចេញទៅ)

សុជាតាអង្គុយម្នាក់ឯង ឥតឆ្លើយតបយ៉ាងម៉េចទៀតឡើយ ព្រោះគិត ថាមិនគួរប្រកាន់ខឹងនឹងមិត្តនារីដូចគ្នាឡើយ ។

## ៥

## ខំប្រឹងព្រោះចង់ជួបមុខ

បីខែមកទៀត... ប្រិក ! ចង់ជួបមុខមីគ្រុកនោះក្រៃលែង តែទាស់មី គ្រុកនោះគ្មានមេត្តា ។ ប្រិកខំប្រឹងបំរើគ្រួសារលោកគ្រូ សុខុមយ៉ាងយកចិត្ត ទុកជាទីបំផុត សល់ពេលខ្លះប្រិកឆ្លៀតទន្ទេញនិងរៀនអក្សរដែលលោកគ្រូដាក់ ឱ្យ ។

ប្រិកយកចិត្តទុកដាក់ណាស់នឹងការរៀនសូត្រ ពីដើមប្រិក ឥតចង់ រៀនទេ ព្រោះប្រិកយល់ថាខ្លួនចាស់ហួសអាយុរៀនសូត្រទៀត ហើយឱ្យតែបាន ជួបមីគ្រុក ហៅយកទៅភូមិវិញរួចធ្វើស្រែ ។ ឥឡូវមិនខំរៀនម្ដេចបាន មីគ្រុក ថា បើឯងមិនចេះមើល នឹងសរសេរអក្សរខ្លួនឯង មីគ្រុកមិនឱ្យស្គាល់មុខជាដាច់ខាត ដូច្នេះបើមិនខំរៀនមុខតែខានបានជួបមីគ្រុក ។ មើលទៅប្រិកគួរឱ្យ អាណិត ថ្ងៃៗធ្វើការឱ្យលោកគ្រូសុខុម យប់ទៅរៀននៅឯវត្តជាមួយចាស់ៗ ។ ដោយការខំប្រឹងព្យាយាមរៀនសូត្ររបស់ប្រិកជាទ្វេងទាត់ មិនយូរប៉ុន្មានប្រិក ចេះស្រៈនឹងព្យញ្ជនៈទាំងអស់ជាស្រេច ឥឡូវនេះ ប្រិករៀនដល់ប្រកបហើយ ប្រិកអាចយកសំបុត្រ មីគ្រុកបណ្ដូលចិត្តគេ មកប្រកបហាត់អានលេងម្ដង ១ ម៉ាត់ ម្ដង១ ម៉ាត់ ដែលជាហេតុនាំឱ្យកូនលោកគ្រូសុខុមសើចចំអកឱ្យ ។ ប្រិក ធ្វើព្រងើយ ត្រង់ណាប្រិកប្រកបមិនកើត ប្រិកសួរប្រពន្ធលោកគ្រូ សុខុម រួច ត្រឡប់ទៅហាត់អានទៀត ។ ប្រិកអរណាស់ដោយឃើញថា ការរៀនសូត្រ របស់គេបានចំរើន លោកគ្រូបង្រៀនអនក្ខរជនតែងតែសរសើរដល់ប្រិកដែលវៃឆ្លាតជាងគេ ។ មិនយូរប៉ុន្មាន ប្រិកអាចអានអក្សរក្នុងសៀវភៅចលនាអក្ខរកម្មបានងាយ តែប្រិកនៅតែខ្សោយខាងនព្វន្ធ គឺការគិតលេខ ព្រោះប្រិកតាំងពី កើតមកមិនដែលបានគិតគូរបូកសងចែកគុណម្ដងណាសោះ ។

សំបុត្រមីគ្រុកបណ្ដូលចិត្តប្រិក ១ ច្បាប់នេះ មានតម្លៃណាស់ រាល់ពេលទំនេរ ប្រិកតែងតែយកលិខិតនេះមកអាន ហើយអានទៀតឥតខ្ជិល ទាល់តែប្រិកចាំមាត់ស្ទាត់អានសូត្របាន។ ប្រិក ហាក់ដូចជាបានបើកភ្នែកពីងងឹត មកភ្លឺច្បាស់វិញ ព្រោះពីដើម ប្រិករមែងតែងអន់ចិត្តនិងមីគ្រុកដែលហ៊ាន សរសេរមកប្រាប់ខ្លួនឱ្យខំរៀន ដោយឥតគិតថាឯងចាស់ហើយ តែឥឡូវនេះ ប្រិកកោតគោរពពាក្យមីគ្រុកក្រៃលែង ប្រិកមិនចង់ជួបមុខមីគ្រុកទៀតទេ ព្រោះខ្មាសមីគ្រុក ដែលមានចំណេះវិជ្ជាជាង ប្រិកទើបតែយល់ថាយើងអាច ក្លាយខ្លួនជាប្ដីគេបានទាល់តែយើងមានប្រាជ្ញាវៃ មានចំណេះវិជ្ជាច្រើនជាងស្រី ទើបសមជាប្ដីគេ ប្រិកឥឡូវនេះ លែងដូចប្រិកពីសម័យមុនហើយ ប្រិកយល់ច្បាស់ក្នុងដំណើរជីវិត ដូច្នេះពាក្យសំដីរបស់មីគ្រុកដែលប្រដៅឱ្យប្រិករៀន ប្រិកដាក់ជិត ព្រះបរមឆាយាល័ក្ខសម្ដេចព្រះបិតាអក្សរសាស្ត្រជាតិ ។ មុនពេលគេង ប្រិកឥតភ្លេចពាក្យបណ្ដាំលោកគ្រូសុខុមឡើយ ប្រិកថ្វាយបង្គំព្រះបរមឆា យាល័ក្ខសម្ដេចឪ រួចលើកសំបុត្រមីគ្រុកមកថើប សំដែងការនឹករលឹក ។

រាល់យប់ប្រិកតែងតែយកសៀវភៅមកហាត់អាននៅមុខតុលោកគ្រូ សុខុមធ្វើការ ដើម្បីឱ្យលោកគ្រូសុខុមបានដឹងថា គេចេះអានអក្សរហើយ តែទាស់ទន្ទេញមេលេខមិនចាំសោះ ប្រិកចេះតែច្រឡំ ។ លោកគ្រូសុខុមខំជួយ ដឹកនាំបង្ហាត់បន្ថែមទៀត ទាល់តែប្រិកបានគ្រាន់បើក្នុងការគិតលេខ ។ ប្រិក បានអួតប្រាប់ប្រពន្ធលោកគ្រូសុខុមថា គេលែងចង់ជួបមុខមីគ្រុកទៀតហើយ ព្រោះគេចង់រៀនឱ្យបានចេះដឹង

ដូចមីគ្រុគ ហើយគេខ្លាចមីគ្រុគខូចចិត្តទៀតផង គេចង់ឱ្យមីគ្រុគរៀនឱ្យច្រើន ដើម្បីជួយស្រោចស្រង់ខ្លួនគេក្នុងការរស់នៅរួមគ្នាក្នុងអនាគតកាល ។

- ប្រិក ! ឥឡូវនេះនិយាយត្រឹមត្រូវល្អណាស់មែនទេប៉ាវ៉ា ? ( ប្រពន្ធ លោកគ្រូសុខុមសួរប្តីគាត់)

- មែន ! ប្រិកចេះដឹងប្លែកជាងពីដើម ( លោកគ្រូសុខុម ឆ្លើយ)

- ប្រិក ! ថ្ងៃណាលោកគ្រូឯងគេឱ្យប្រឡង ? ( ប្រពន្ធ លោកគ្រូ សុខុមសួរ)

- បាទអ្នក ! ខ្ញុំឮថាខែក្រោយ

- ចុះឯងមានសង្ឃឹមប្រឡងជាប់និងគេទេ ? ( ប្រពន្ធ លោកគ្រូ សុខុមសួរទៀត)

-មិនដឹងយ៉ាងណាទេអ្នក ! ខ្ញុំខ្លាចតែលេខទេ បើសរសេរអក្សរ នឹង អានសៀវភៅ ខ្ញុំឥតខ្លាចទាល់តែសោះ ( ប្រិកឆ្លើយ)

- ឯងមិនបាច់សង្ស័យទេ អាប្រិកវាមុខតែជាប់ហើយ ព្រោះវាខំរៀនណាស់ ( លោកគ្រូសុខុមឆ្លើយជួស)

- ប្រិក ! ប្រិកឯងជឿខ្ញុំទេ ខ្ញុំថាឱ្យតែព្យាយាមរៀនសូត្រមិនថា ចាស់ ឬក្មេងទេ ឱ្យតែរៀនមុខតែចេះមិនខាន ទោះតិចក្តីច្រើនក្តី ឥឡូវនេះ ប្រិកឯងចេះអក្សរអាចមើលដឹងរឿងរ៉ាវផ្សេងៗបានទាំងអស់ ឯងទៅភ័យអីទៀត មីគ្រុគមុខតែឱ្យឯងបានឃើញមុខវាជាមិនខាន ព្រោះវាបានសន្យាថា កាលណាឯងចេះមើលនឹងចេះសរសេរអក្សរខ្លួនឯង វានឹងបង្ហាញខ្លួនវាឱ្យឯងស្គាល់មិនខាន ( លោកគ្រូសុខុមបន្ថែម)

- បាទលោកគ្រូ ! ខ្ញុំចង់រៀនឱ្យបានច្រើន ដើម្បីកុំឱ្យខ្មាស មីគ្រុគ ព្រោះមីគ្រុគវាបានសន្យាថា វាមិនលះបង់ខ្ញុំបាទឡើយ ( ប្រិកឆ្លើយ)

- មិនអីទេប្រិក កាលណាឯងប្រឡងខាងអក្ខរជនជាប់ អញទៅសុំ លោកចាងហ្វាងឱ្យឯងចូលរៀនថ្នាក់មជ្ឈិមដ្ឋានតែម្តង តែបីឆ្នាំទៀតឯងអាច ចេះជ្រៅជ្រះជាងសព្វថ្ងៃ ហើយឯងបានចេះអក្សរបារាំងទៀត ឯមីគ្រុគឯងក៏ជិតដល់ឆ្នាំប្រឡងឌីប្លូមដែរ ។ បើឯងស្រឡាញ់ការរៀនសូត្រដូច្នេះអញសង្ឃឹមថា ឯងមុនជាបានសម្រេចជាប្រាកដ ( លោកគ្រូសុខុមប្រដៅ)

- បាទលោកគ្រូ ! ខ្ញុំបាទត្រេកអរណាស់ កាលបើបាន លោកគ្រូ ជួយ អាណិតស្រណោះខ្ញុំបាទដូច្នេះ ( ប្រិកឆ្លើយយ៉ាង សុភាព)

- ឯងកុំព្រួយ ! អញចូលចិត្តអ្នកណាស្រឡាញ់ការរៀនសូត្រ ពិសេសមនុស្សដូចឯង អញចង់ឱ្យឯងមានការចេះដឹង ហើយយកការចេះដឹងឯងនេះ ទៅបើកភ្នែកបងប្អូនឯងនៅឯស្រុកភ្នំឱ្យបានស្គាល់អក្សរសាស្ត្រជាតិនឹងគេ ដូចជាមីគ្រុគឯងនិយាយនោះចំជាត្រូវណាស់ ។

- មែនលោកគ្រូ ! មីគ្រុគខ្ញុំបាទចេះនិយាយត្រូវល្អណាស់ ខ្ញុំបាទរឹតតែ ស្រឡាញ់វាខ្លាំងឡើងទៀត កាលណាខ្ញុំបាទសម្រេចក្នុងការរៀនសូត្រ ។

- ចុះឥឡូវនេះឯងមិនចង់ជួបវាទេឬ ?( លោកគ្រូសុខុម សួរប្រិក លេង)

- បាទលោកគ្រូ ! ខ្ញុំបាទមិនទាន់ចង់ជួបវាទេ ព្រោះកុំឱ្យខុសសន្យា ចាំថ្ងៃណាវាថាខ្ញុំបាទល្មមជួបវាបាន ចាំថ្ងៃនោះខ្ញុំបាទសុំវា ជួបតែម្តង ហើយនាំគ្នាទៅភូមិរៀបការតែម្តង ។

- ឯងនិយាយនេះត្រូវហើយប្រិក អញពេញចិត្តណាស់ មនុស្សយើង ទាល់តែចេះយល់ចិត្តថ្លើមគ្នាដូច្នេះ ទើបហៅថាស្រឡាញ់គ្នា ។

-ចុះបើទំរាំឯងរៀនបានការធ្វើមីគ្រុគឯងគេបែកចិត្តស្រឡាញ់អ្នកណាទៅទៀតឯងមិនខកទៅហើយ( ប្រពន្ធលោកគ្រូសុខុមចោទមកទៀត )

- បាទអ្នក ! ខ្ញុំបាទដូចជាលែងគិតទៅហើយ ព្រោះគេមានសិទ្ធិគ្រប់ គ្រាន់និងរើសប្តី ឯខ្ញុំបាទវិញក៏មានសេរីភាពអាចរកប្រពន្ធថ្មីទៀតបានដែរ ( ប្រិកឆ្លើយ)

- ដូច្នេះមិនខុសនិងទំនៀមទំលាប់ស្រុកឯងទៅហើយ ?

- បាទអ្នក ! ខុសនោះវាពិតជាខុសទៅហើយ តែឱ្យខ្ញុំបាទធ្វើដូចម្តេច បើគេឈប់ស្រឡាញ់ខ្ញុំបាទ ហើយម្យ៉ាងទៀតខ្ញុំបាទចេះដឹងប៉ុណ្ណេះទៅជឿធ្វើអ្វី រឿងបើគ្រាន់តែរកប្រពន្ធនោះ ( ប្រិកឆ្លើយយ៉ាងស្រងូតស្រងាត់) ។

- ណ្ហើយ ! ប្រិកអើយ ឯងខំតែរៀន ហើយត្រូវមានសង្ឃឹមជាដរាប ព្រោះក្នុងសំបុត្ររបស់គូប្រចាំជីវិតឯងនោះគេថា ទោះបីយ៉ាងណាក៏ដោយគេ មិនបោះបង់ឯងចោលដែរ ឯងត្រូវតែខំតស៊ូរៀនសូត្រទៅ (លោកគ្រូសុខុមកាត់ សេចក្តី) ។

- បាទលោកគ្រូ ! ខ្ញុំបាទផ្សងតាមវាសនាទៅចុះ បើពិតជាគូខ្ញុំបាទ ទោះយ៉ាងណាក៏បានសម្រេចដូចបំណងដែរ ។

- ត្រូវហើយប្រិក ! មនុស្សយើងឱ្យតែមានវិជ្ជា គឺមានទ្រព្យ បើ មានទ្រព្យតើសុភមង្គលរត់ចោលឯងទៅណារួច ឯងមិនត្រូវព្រួយច្រើនទេ ។

- យប់យូរណាស់ហើយប្រិក ឯងលុមទៅសំរាកហើយ ស្អែកក្រោកពីព្រឹកដងទឹកដាក់ពាងឱ្យពេញគ្រប់ទាំងអស់ផងទេ រួចជំរះស្មៅតាមជើងរបងឱ្យ ស្អាតផង ។

- បាទលោកគ្រូ ! ខ្ញុំបាទសូមទទួលបំរើលោកគ្រូគ្រប់បែបយ៉ាង សូមលោកគ្រូកុំព្រួយ ។

## ៦

## ភ្លេចគិតព្រោះខាប់រៀនសូត្រ

ក្នុងរយៈកាលដែលប្រិកនៅបំរើលោកគ្រូសុខុម ការសិក្សារបស់ប្រិក ក៏មិនខុសពីដំណក់ទឹកត្នោត ដែលធ្លាក់ក្នុងបំពង់ដែរ ។ មួយថ្ងៃបន្តិចៗ ប្រិកចេះ អានអក្សរយ៉ាងច្បាស់ ស្គាល់ពាក្យខ្ពស់ ទាប ។ ឥឡូវនេះប្រិកបានចូលរៀន សាលាបឋមសិក្សាបំពេញវិជ្ជាក្រចេះហើយ ។ ពិតមែនតែខ្លួនប្រិកធំជាងក្មេង ដទៃទៀត តែប្រិកនៅតែខំរៀនឥតអៀនខ្មាសឡើយ ។ លោកគ្រូសុខុមបានផ្សាយករុណាធម៌ចំពោះ យុវជនរូបនេះក្រៃលែង ដោយគ្មានគិតប្រយោជន៍ផ្ទាល់ខ្លួន រក្សាប្រិកទុកបំរើការក្នុងគ្រួសារ ស៊ូឱ្យប្រិកទៅរៀនសូត្រជួយប្រាក់កាសសព្វយ៉ាង ដែលប្រិកត្រូវការដូចជាឪពុកនឹងកូន ។

ឯប្រិកវិញ ពិតមែនតែមានកំណើតនៅជ្រកភ្នំ ប៉ុន្តែប្រិកមានគំនិតចេះ បំរើគេប្តូរយកតំរេះ គួរជាទីពេញចិត្តដែរ ។

មួយឆ្នាំហើយមួយឆ្នាំទៀត កាលវេលាក៏បានកន្លងទៅ ការសិក្សា របស់ប្រិក ក៏បានចំរើនតាមឆ្នាំនៃថ្នាក់ជាលំដាប់ដែរ ។ ឆ្នាំនេះ ប្រិកត្រូវបានប្រឡងចូលអនុវិទ្យាល័យនឹងគេហើយៗជាមួយនេះ នរណាក៏ភ្លេចឥតបានគិត ដល់រឿងដើមរបស់ប្រិកទៅហើយ ព្រោះប្រិកឥតសួររកឬដេញដោលយ៉ាងណាៗទៀតទេ រាល់ថ្ងៃក្រៅពីរៀនសូត្រនៅសាលា ប្រិកឥតឱ្យពេលវេលាកន្លង ទៅដោយឥតប្រយោជន៍ ប្រិកខំទន្ទេញខំស្វាធ្យាយសិក្សាឥតធុញថប់ ។ តើនរណាជឿបានថាប្រិកមានគំនិតដល់ប៉ុណ្ណេះ ។ ប្រិកជាមនុស្សស្រុកភ្នំតាមរកគូដណ្តឹង ឥឡូវនេះគ្រួសារលោកគ្រូសុខុម ដែលពីដើមឮតែប្រិកត្អូញត្អែរសួររក មីគ្រុកគ្មានលោះខានថ្ងៃណា ឥតដែលបាននឹកដល់រឿងនោះទៀតទេ ព្រោះគេលែងទាំងជឿ ប្រិកថាមានគូដណ្តឹងជាប្រាកដផងទៅហើយ ។

សព្វថ្ងៃនេះឃើញតែប្រិកខំរៀន ឥតនិយាយស្តី ឥតដើរលេងផ្តេសផ្តាស ឥតស៊ីចាយ ឥតហ៊ឺហារទាល់តែសោះ ម្ល៉ោះហើយ ប្រិកក៏ក្លាយខ្លួនទៅជា គ្រួសារលោកគ្រូសុខុមជាប្រាកដ ព្រោះគេលែងទុកប្រិក ជាមនុស្សផ្តេសផ្តាស គ្មានការចេះដឹងទៀតឡើយ ។

ទើបតែល្ងាចថ្ងៃនេះ នៅពេលគ្រួសារលោកគ្រូសុខុមកំពុងទទួល អាហារជួបជុំគ្នា ប្រពន្ធលោកគ្រូសុខុមកំពុងធ្លោយ សួរប្រិកលេងពីរឿងមីគ្រុក :

- ប្រិក ! ប្រិក ដូចជាភ្លេចមីគ្រុកស្អីឯងនោះបាត់ឈឹងទៅហើយមែន ទេ ?

- បាទអ្នក ! ខ្ញុំបាទឥតហ៊ានសួររកទៀតទេ ព្រោះគេរៀនបានច្រើន ជាងខ្ញុំ ហើយកាលពីវាំកងឆ្នាំទៅ វាទៅស្រុកវាដើរប្រាប់គេថា បើខ្ញុំមិនខំរៀន ឱ្យចេះប្រហែលវាទេ វាមិនព្រមទទួលខ្ញុំបាទធ្វើប្ដីវាទេ ព្រោះវាខ្មាស់គេណាស់ បានប្ដីល្ងង់ដូច្នោះនោះ ។ ឪពុកខ្ញុំបាទ ដែលគាត់មកលេងពីឆ្នាំទៅ បានប្រាប់ខ្ញុំ បាទសព្វគ្រប់ពីរឿងមីគ្រុកខ្ញុំបាទ គាត់បន្ថែមទៀតថា មីគ្រុកឥឡូវនេះធំ ហើយស្អាតជាងគេទាំងអស់ ។ ខ្ញុំបាទចង់ឃើញមុខវាដែរ តែដូចជាខ្មាសវាណាស់ ព្រោះវាមើលងាយខ្ញុំបាទ ។

- ដូច្នេះមីគ្រុកមានជាប្រាកដ ឬប្រិក ? ហើយវារៀននៅសាលា ក្រចេះមែនទេ ? (ប្រពន្ធលោកគ្រូសុខុមសួរបញ្ជាក់)

- បាទអ្នក ! សព្វថ្ងៃនេះ នៅគេងបាយទឹកក្នុងសាលាយើងនេះ តែវាកោងណាស់វាមិនចង់ឱ្យខ្ញុំជួបវាទេ ។ កាលពីអាទិត្យមុន ខ្ញុំទៅលេងពួកម៉ាកខ្ញុំ ម្នាក់នៅរៀនអនុវិទ្យាល័យដែរខ្ញុំចេះតែគយគន់រកវាដែរ តែមិនឃើញសោះ ។ ខ្ញុំបានសួរអាពួកម៉ាកខ្ញុំ តែអានេះវាថា មីគ្រុកបានហាមជាដាច់ខាតមិនឱ្យវាចង្អុលរូបវាប្រាប់ខ្ញុំទេ ។ ខ្ញុំខឹងនិងវាណាស់ មិនគួរដាច់ចិត្តដល់ប៉ុណ្ណឹងសោះ ខ្ញុំខំមករកវាចោលស្រុក ចោលទេសមិនគួរវាមានចិត្តអាក្រក់ដូច្នេះ ។ ម្យ៉ាងទៀត វាបានផ្ដាំនិងអាពួកម៉ាកខ្ញុំថា ឱ្យតែខ្ញុំខ្ជិលរៀន វានិងរកគូកំណាន់ចិត្តថ្មីទៀត ភ្លាមវាមិនព្រមចាប់ដៃខ្ញុំទេ ហើយវាមិនខ្លាចខុសប្រពៃណី ឬទំនៀមទំលាប់ មនុស្សស្រុកភ្នំទាល់តែសោះ ព្រោះវាជាសិស្សសាលា រៀនសូត្រចេះដឹងត្រូវតែស្គាល់ល្អអាក្រក់ដូច្នេះ ។

- ចុះឯងបានផ្ដាំពាក្យអីទៅវិញ ឬទេ ? (លោកគ្រូ សុខុមសួរ)

- បាទលោកគ្រូ ! ខ្ញុំបាទគ្រាន់តែថា បើវាមិនស្រឡាញ់ខ្ញុំបាទទេ ក៏ ឈប់ចុះ ព្រោះខ្ញុំបាទក៏កំពុងខំរៀនសូត្រដូចបណ្ដាំវាដែរ ធ្វើម៉េចបើខ្ញុំបាទរៀនក្រោយវា ឱ្យទាន់វាឯណាបាន ។ ម្យ៉ាងទៀត ខ្ញុំបាទក៏ធ្វើជានិយាយផ្ដាំទៅវិញថា បើវារកគូកំណាន់ថ្មី ខ្ញុំបាទមិនចេះរកស្រីកំណាន់ថ្មីដែរខ្វះអីឱ្យតែខ្ញុំបាទខំរៀន ។ ស្រាប់តែពីខែមុនអាពួកម៉ាកខ្ញុំបាទនោះ វារត់មករកខ្ញុំវិញកាន់ ទាំងសំបុត្រមីគ្រុក ក្នុងនោះវាថា វាមិនមែនចង់លះបង់ចោលខ្ញុំបាទទេ វានិយាយថា វាអរណាស់កាលបើឃើញខ្ញុំបាទខំរៀន វាសង្ឃឹមថាថ្ងៃក្រោយវា នឹងរកសុភមង្គលឃើញហើយ ។

- អីយ៉ា ! បងប្រិកចេះពាក្យសុភមង្គលផង (កូនច្បង លោកគ្រូ សុខុម អស់សំណើច)

- កុំមាត់អាសុភាព ! ឯងថាប្រិកល្ងង់ណាស់ទៅឬ? (លោកគ្រូសុខុម ស្រែកឱ្យកូនគាត់)

- យ៉ាងម៉េចទៅទៀតប្រិក រឿងឯងដូចជាពិរោះគ្រាន់បើ (ប្រពន្ធ លោកគ្រូសុខុមសួរ)

- បាទអ្នក ! រួចវាថា កាលណាវាប្រឡងឌីប្លូមជាប់ វានឹងសុំរាជការ ធ្វើគ្រូបង្រៀនឬពេទ្យ ហើយសុំផ្លាស់ទៅស្រុក ។

- ដូច្នេះឯងមានគំនិតដូចម្ដេចទៅវិញ បើគេថាដូច្នេះ ?

- បាទលោកគ្រូ ! ខ្ញុំបាទយល់ថា វាគិតនេះត្រឹមត្រូវល្អណាស់ ។ កាលណាវាបានការធ្វើនោះ វាលះបង់ខ្ញុំបាទចោលទៅយកអ្នកណាដទៃទៀតក៏មានឈ្មោះថា ក្មេងមកពីស្រុកលើចេះខំរៀនទាល់តែបានការធ្វើដូចគេដូចឯងដែរ ។ ខ្ញុំបាទក៏ជួយអរវា ។

- ចុះឯងមិនស្ដាយវាទេ បើឯងខំស្រឡាញ់វាតាំងពីយូរមកហើយ ដល់វាបានការធ្វើទៅយកអ្នកដទៃទៅវិញ ?

- បាទលោកគ្រូ ! ស្ដាយធ្វើអ្វី បើគេមិនស្ដាយយើងៗក៏មិនត្រូវស្ដាយ គេវិញដែរ ។

- ឯងនិយាយត្រូវ ដូច្នេះឯងចង់ឈប់រៀនអង្កាល់ ?

- បាទលោកគ្រូខ្ញុំបាទឥតទាន់ចង់ឈប់ទេ ឱ្យតែលោកគ្រូ នឹងអ្នក មានមេត្តាជួយខ្ញុំបាទឱ្យរៀន ខ្ញុំបាទតស៊ូទាល់តែបានដូច មីគ្រុក កុំឱ្យវាមើលងាយបាន (ប្រិកនិយាយយ៉ាងស្រងូតស្រងាត់ហាក់ដូចអស់សង្ឃឹម)

- មិនអីទេប្រិក ! កាលណាឯងចង់រៀន ចេះតែខំរៀនទៅ អញនិង ជួយឯងលុះដល់ចុងក្រោយបំផុត ហើយអញនិងទៅស្ដីដណ្ដឹងមីគ្រុកឱ្យឯងម្ដងទៀត បើសិនជាឯងចង់ពឹងអញ ។

- ប្រិកលុតជង្គង់សំពះលោកគ្រូសុខុម ថ្លែងអំណរគុណ ហើយពោល ថា :

- លោកគ្រូ ! អ្នក ! ខ្ញុំបាទនៅជំពាក់គុណលោកគ្រូច្រើនណាស់ ពុំ ទាន់បានសងវិញបន្តិចឡើយ ។ និយាយលាក់បាំងអ្វី សព្វថ្ងៃនេះកុំតែខ្ញុំបាទនឹកៗ ទៅដូចជាខ្មាសមីគ្រុគពេក កុំអីខ្ញុំបាទមិនតស៊ូរៀនទេ ព្រោះខ្ញុំបាទធំហើយ គួរតែនៅបំរើលោកគ្រូឱ្យបានជិតដល់ ដើម្បីតបស្នងសងគុណលោកគ្រូ ។ ខ្ញុំបាទនឹងខំរៀនឱ្យបានសម្រេច បើឆ្នាំនេះប្រឡងមិនជាប់ ឆ្នាំក្រោយខ្ញុំបាទខំរៀន ទាល់តែប្រឡងជាប់មិនខាន ។

- អើ ! ចុះឆ្នាំនេះ មីគ្រុគឯង គេដល់ឆ្នាំប្រឡងឌីប្លូមហើយឬនៅ ?

- បាទលោកគ្រូ ! ដល់ឆ្នាំនេះហើយ.... ប្រហែលជាវាប្រឡងជាប់ ព្រោះឮថាវារៀនពូកែណាស់ ។ ចុះប្រិកឯង ! ឆ្នាំនេះសង្ឃឹមបានចូលអនុវិទ្យា ល័យនិងគេទេ ?

- បាទលោកគ្រូ ! សង្ឃឹមបន្តិចបន្តួច ។

- អើ ! ខំរៀនទៅ នៅតែបន្តិចទៀតឯងនឹងបានទាន់គូដណ្ដឹងឯង ហើយ ។

ដោយឃើញថា នាំគ្នាយករឿងចាស់មកឱ្យប្រិករំលឹកឡើងវិញ ដូច្នេះ ដែលជាហេតុនាំឱ្យប្រិកមានគំនិតរវើរវាយរៀនសូត្រទៅមុខទៀតមិនកើត គ្រួសារលោកគ្រូសុខុមក៏បញ្ចប់ការពិភាក្សាត្រឹមនេះ ហើយដេញប្រិកឱ្យទៅ រៀនសូត្រទៅ ។

## ៧

## បណ្ដាំមុនពេលឃ្លាតឆ្ងាយ

យប់នេះព្រះច័ន្ទនៅលើមេឃ បានបញ្ចេញរូបរាងយ៉ាងសង្ហាគួរឱ្យគយគន់ក្រៃលែង ។ អ្នកមានមនោសញ្ចេតនាវែងឆ្ងាយចូលចិត្តរំលឹករឿងចាស់ ឬរឿងផ្ទាល់ខ្លួន ហើយស្រឡាញ់ដួងព្រះច័ន្ទណាស់ ព្រោះគេចូលចិត្ត គេពេញចិត្ត ព្រមទាំងមានចិត្តស្មោះស្ម័គ្រហ៊ាននិយាយការពិតប្រាប់ព្រះច័ន្ទទៀតផងម្ល៉ោះហើយព្រះច័ន្ទពុំអាចឃ្លាតឆ្ងាយពីប្រសៃភ្នែកនៃមនុស្សជំពូកនេះឡើយ ។

អ្នកណាក៏ដូចជាអ្នកណា ប្រិកក៏ដូចជាជនទូទៅក្នុងពិភពលោកដែរ ដូច្នេះយប់នេះប្រិកក៏ស្រឡាញ់ដួងព្រះច័ន្ទដែរ ប្រិក ក្រោយដែលទទួលទានអាហាររួច ក៏ចុះពីលើផ្ទះមកអង្គុយលើគ្រែកញ្ចាស់មួយ ដែលលោកគ្រូសុខុម ដាក់ចោលគៀនផ្ទះ ។ ប្រិកនឹកឃើញអស់ហើយនឹកឃើញដល់ជួរភ្នំទាំងឡាយ ដែលដុះស្មៅយ៉ាងខៀវស្រងាត់ ជ្រោះភ្នំដែលសម្បូរណ៏ទៅដោយសត្វសាហាវ ហើយគេហ៊ានលបចូលទៅបាញ់ ។ មិត្តភ័ក្រ្តទាំងឡាយដែលធ្លាប់បឺតស្រា ឡក របាំជាមួយគ្នា រហូតនឹកដល់មីគ្រុគ ដែលជាគូកំសត់ម៉ែទុកឪពុកដាក់ ។ មនោសញ្ចេតនារបស់ ប្រិកលឿនរហូតដល់នឹកថា មីគ្រុគពុំគួរចិត្តដាច់ធ្វើមិនស្គាល់ គេសោះ ហើយបង្ខំឱ្យគេខំរៀនទៀត ហេតុតែឯងស្រឡាញ់គេយ៉ាងស្មោះអស់ ពីពោះទោះគេឱ្យធ្វើអ្វីក៏ព្រមទទួលធ្វើដែរ តែចុះហេតុអ្វីក៏គេមិនយល់ចិត្តឯងទៀត ។ ប្រិកអង្គុយភ្លេចខ្លួនរំលឹករឿងខ្លួនឡើងវិញ ដែលពុំបានជាដឹងថាមានមិត្តគេម្នាក់ដែលជាជនខ្មែរលើដែរនោះ មកឈរនៅស្ងៀមធ្វើព្រងើយ ។

លុះយល់ថា ប្រិកអង្គុយស្ងៀមឥតងើយមុខសោះដូច្នេះ ក្រាញ់ក៏លូកដៃកេះខ្នងប្រិកធ្វើឱ្យប្រិកភ្ញាក់ព្រើត ស្ទុះក្រោកឡើងតាំងគុនតាមក្បាច់ខ្មែរ លើម្នាក់ឯង បណ្ដាលឱ្យគ្រួសារលោកគ្រូ សុខុមសើចលាន់ឡើង ។ ប្រិក អៀនខ្លួនស្ទុះទៅជិតក្រាញ់ ហើយសួរយ៉ាងរាក់ទាក់ថាៈ យើក្រាញ់ ! ឯងមកពីអង្កាលបានជាមិនមាត់មិនក។ ឯងមានការស្អីហ្នឹង ! បានជាថ្មើរណើងមកដល់ ។ យ៉ាងណាទៅ ? ឯងប្រឡងជាប់ ដែរឬទេឌីប្លូមនោះ ចុះមីគ្រុគ អញ្ចូជាប់ទេ ?

- បងប្រិកអើយ ! ខ្ញុំប្រឡងជាប់ហើយ ពួកយើងដែលមកពីលើ ប្រឡងជាប់បាន ៦នាក់ ស្រី ២នាក់ នឹងប្រុស ៤នាក់ ។

ឮប៉ុណ្ណេះប្រិកប្រហោងពោះធ្លុង ព្រោះមិនដឹងជាសង្សារគេប្រឡង ជាប់ឬធ្លាក់ ក៏បញ្ឆាក់សួរទៀត ។

- អ្នកណាខ្លះប្រឡងជាប់ ?

- បងប្រិក ! គូដណ្តឹងបងប្រិកឯង គេប្រឡងជាប់ហើយ ហើយគេ បានពឹងខ្ញុំឱ្យយកសំបុត្រនេះ មកឱ្យបងប្រិកឯង ដូច្នេះបងប្រិកឯងមុខជាបាន ជួបគេមិនខាន និយាយចប់ក្រាញ់ក៏លូកយកសំបុត្រមួយមកឱ្យប្រិក ។

ឥតមាត់កអ្វីមួយមាត់ ប្រិកយកសំបុត្រនេះឡើងលើផ្ទះ ហើយហែក អានភ្លាមដោយឥតអៀនខ្មាសដល់អ្នកឡើយ ។

ថ្ងៃទី ១៥ មិថុនា ឆ្នាំ ១៩៦០

មកដល់បងប្រិក

បង ! អូនមានភ័ព្វសំណាង បានប្រឡងជាប់ហើយៗបានលទ្ធផលល្អទៀតផង ដូច្នេះសូមបងទទួលដំណឹងយ៉ាងរីករាយ នេះជាមួយអូនផងចុះ ។

ប្រិកបង ! អូនសប្បាយចិត្តណាស់ កាលបើអូនឃើញការសិក្សា របស់អូនទទួលរង្វាន់ល្អដូច្នេះ តែអូនព្រួយទៅវិញដោយពុំទាន់បានដឹងថាបងរៀនសូត្របានដល់ណាហើយសព្វថ្ងៃនេះ ព្រោះអូនមានសង្ឃឹមថា ទោះបីយ៉ាងណាក៏បងខំប្រឹងរៀនសូត្រឱ្យទាល់តែបានសម្រេចលទ្ធផលល្អជាពុំខាន ។

ប្រិកបង ! អូនសូមជំរាបបងថា បីថ្ងៃទៀតអូនត្រូវលាចាកសាលា ទៅកាន់ទីក្រុងភ្នំពេញ ដើម្បីទៅសុំរាជការមានសមត្ថកិច្ចធ្វើជាគ្រូបង្រៀនដោយអូនបានដឹងថា រាជការមុខជាទទួលអូនឱ្យចូលក្នុងដំណែងនេះជាពុំខាន ។ បើប្រសិនជាអូនបានទទួលតំណែងថ្មីនេះជាប្រាកដ អូននឹងសូមរាជការត្រឡប់ ទៅស្រុកកំណើតវិញមុនបងហើយ ។

ឆ្នាំនេះបងប្រឡងចូលអនុវិទ្យាល័យហើយ សូមបងខំប្រឹងប្រែងឱ្យ មែនទែន ។

បង ! ឥឡូវនេះការសិក្សារបស់អូនសន្មត់ថាចប់ហើយ ដូច្នេះអូនអាច អនុញ្ញាតឱ្យបងស្គាល់រូបអូនបាន ។ ដើម្បីកុំឱ្យបងកើតទុក្ខព្រោះតែអូនតទៅ ទៀត ។

ប្រិកបង ! ស្អែកនេះ អូននឹងមិត្តអូននិងមកលេងផ្ទះ លោកគ្រូ "សុខុម" ជាមិនខាន ដើម្បីជំរាបលាលោកគ្រូទៅនៅភ្នំពេញដូច្នេះសូមបង ចាំទទួលអូនផង ,

សួស្តីបង

ហត្ថលេខា សុជាតា

លុះអានចប់ភ្លាម ប្រិកលោតទះដៃស្រែកថា មីគ្រុគខ្ញុំប្រឡងជាប់ ហើយ វាពិតជាមិនបំភ្លេចខ្ញុំទេ ព្រោះវានៅរលឹកខ្ញុំដែរ ។ ប្រិកអរណាស់ អររកអ្វីមកប្រដូចពុំបាន ។ លោកគ្រូសុខុម នឹងគ្រួសារជួយអរប្រិកគ្រប់ៗគ្នា ។ ទើបតែថ្ងៃនេះទេ ដែលទាំងអស់គ្នាព្រមជឿថានៅក្នុងអនុវិទ្យាល័យនេះ មានមីគ្រុគរបស់ប្រិកមែន ។ ឥឡូវនេះគេសន្យាថា ស្អែកគេមកលេងលោកគ្រូទៀតផង (ប្រិកអរពេក និយាយក្អេងក្អាង ជំរាបលោកគ្រូ) ។

- អញដឹងហើយប្រិក ! អញបានឮសព្វគ្រប់អស់ហើយ កាលដែល ឯងអានសំបុត្រអម្បាញ់មិញ ។

- ប្រិកលាសំបុត្រនេះអានម្តងទៀត លុះចប់ហើយក៏អានម្តងទៀត ដូចជាពុំចេះស្កប់ចិត្តសោះ ។

- ប្រិក ស្អែកគេមករកឯងហើយ តើឯងបានអ្វីចងដៃគេបើគេប្រឡង ជាប់ដូច្នេះ ?(លោកគ្រូសួរ)

- គ្រាន់តែឮសំនួរនេះភ្លាម ប្រិកធ្លាក់ទឹកមុខឥតនិយាយស្តី គិតមួយ សន្ទុះទើបឆ្លើយថា :

- បាទលោកគ្រូ ! ខ្ញុំបាទដូចជាមិនចង់ឱ្យវាមកជួបខ្ញុំបាទទេ ព្រោះនឹកៗទៅដូចជាខ្មាសវាផង ម្យ៉ាងទៀតគេជិតបានធ្វើអ្នកគ្រូទៅហើយ ឯងមិនដឹងជានៅឯណា ។

- ម៉េចអញ្ជឹងប្រិក ! ដល់បានជួបគេហើយ ទៅជាមិនចង់ជួបទៅវិញ (ប្រពន្ធលោកគ្រូសុខុមឆ្លើយ)

- អ្ហឺ ! វាឈ្មោះអីទៅសាលាប្រិក ? (លោកគ្រូសុខុម សួរ)

- បាទលោកគ្រូ ! នេះវាដាក់ចុងក្រោយថា ហត្ថលេខា សុជាតា ។

- ឱ ! សុជាតាទេ គឺមីគ្រុគឯងនោះ (លោកគ្រូសុខុមភ្ញាក់ ព្រោះធ្លាប់ ស្គាល់សុជាតាញឹកញាប់ តែមិនដឹងថាសុជាតាជា មីគ្រុគសោះ)

យប់នេះ ប្រិករឹតតែស្រឡាញ់ព្រះច័ន្ទខ្លាំងឡើងទៅទៀត ព្រោះក្នុងរង្វង់នៃផ្ទៃលោកខែ ប្រិកសំឡឹងយូរៗទៅឃើញរង្វង់មុខដ៏ផូរផង់របស់មីគ្រុគ ដែលប្រិកទើបតែបានស្គាល់ ។ ប្រិកចេះតែវឹរវាយ គេងមិនលក់ទេ ។ ប្រិកបន់ឱ្យតែភ្លឺឆាប់និងបានជួបស្រស់ស្រីបណ្ដូលចិត្តគេ ។ ចិត្តប្រិកតែងរិះរេគ្រប់ជំពូក ជួនប្រិកនឹកថាមិនត្រូវជួបនឹងមីគ្រុគបណ្ដូលចិត្តគេក្នុងបច្ចុប្បន្ននេះទេ ព្រោះគេពុំទាន់បានសម្រេចការរៀនសូត្រ តែចិត្តមួយមកឃាត់ថា ត្រូវតែឱ្យជួបឱ្យបានស្គាល់មុខគ្នាឱ្យច្បាស់សិន ទោះល្អ អាក្រក់ អៀនខ្មាសអ្វីក៏ដោយ ។

ព្រឹកនេះ ប្រិកស្លៀកពាក់ស្អាតបាតចុះឡើងៗ ចេញចូលៗ ពីលើទៅ ក្រោម ដូចជារកអង្គុយមួយកន្លែងឱ្យស្ងៀមមិនកើតសោះ ។ នាឡិកាភ្លេងមួយ គ្រឿងព្យួរនៅជញ្ជាំងលើផ្ទះលោកគ្រូ សុខុមបានវាយសញ្ញាថា ម៉ោងប្រាំបីទៅហើយ មីគ្រុគបណ្ដូលចិត្ត ប្រិកក៏មិនទាន់មកទៀត ចិត្តប្រិករវោមម្ដងនឹកថា គេ ភរ ម្ដងនឹកថាប្រហែលមកមិនទាន់ដល់ ។ ចិត្តប្រិកសែនអន្ទះអន្ទែងផង ព្រោះបួនឆ្នាំបានកន្លងផុតទៅ ហើយដែលប្រិកស៊ូលះបង់ស្រុកកំណើត មករង់ចាំតែ ស្រស់ស្រីបណ្ដូលចិត្តគេម្នាក់នេះ ទើបតែថ្ងៃនេះទេដែលគេមានវាសនាត្រូវបានជួប ។

មួយស្របក់ក្រោយមក នៅទីធ្លាមុខផ្ទះលោកគ្រូសុខុម មានកញ្ញា ៣នាក់ ឈរវេរាហាក់ដូចជារកអ្នកណាម្នាក់ ។ បេះដូងប្រិកហាក់ដូចជាយោល កាន់តែខ្លាំង ។

- ជំរាបសួរពូ ! (កញ្ញាមួយរូបចូលមក ហើយលើកដៃសំពះប្រិក)

- បាទ ! នាងមករកអ្នកណា ?(ប្រិកសួរតបវិញ)

- ចាំ ! អ្នកមីងប្រពន្ធលោកគ្រូសុខុមនៅផ្ទះទេ ? (នាងបន្តសួរមក ទៀត)

- បាទ ! គាត់នៅឯផ្ទះបាយឯណោះ ! ប្រិកឆ្លើយព្រមទាំងសំឡឹង នារី ២រូបទៀត ដែលនៅឈរស្ងៀមឯមាត់ទ្វាររបង

- មក៏សុជាតា ! សុភាព ! អ្នកមីងនៅលើផ្ទះឯណោះចូលមក (កញ្ញា រូបនេះស្រែកហៅមិត្តនារីគេ)

- ប្រិកគ្រាន់តែឮពាក្យសុជាតា ដែលធ្លាយចេញពីមាត់នារីនេះភ្លាម ចិត្តប្រិកហាក់លែងនៅស្ងៀម បេះដូងក្នុងដើមទ្រូងប្រិកហាក់យោលលឿនខុសប្រក្រតី ។

- ជំរាបសួរបង ! បងប្រិក (សុជាតា នឹងសុភាពចូលមកជិតប្រិក ហើយសំដែងការគួរសម)

ប្រិកឥតឆ្លើយនៅស្ងៀម ហាក់ហារមាត់ឆ្លើយមិនរួច (កញ្ញាទាំងបី រូបនេះក៏ចូលផុតទៅ)

- ជំរាបសួរអ្នកមីង !

- ចាំនាង ! ម៉េចទៅនាង ? នាងណាខ្លះប្រឡងជាប់ ? (ប្រពន្ធ លោកគ្រូសុខុមសួរ)

- ចាំអ្នកមីង ! សុជាតា នឹងខ្ញុំប្រឡងជាប់ (សុភាពឆ្លើយ ព្រមទាំង ចង្អុលទៅសុជាតា ដែលនៅស្ងៀមរកនិយាយអ្វីក៏មិនរួចដែរ)

- ចុះនាងឯណោះជាប់ទេ ?

- ចាំអ្នកមីង ខ្ញុំក៏ជាប់ដែរ

- ចាំអ្នកមីង ! វិណាគេពុំមែនមកពីលើទេ គេជាអ្នកស្រុកក្រចេះ យើងនេះទេ (សុភាពឆ្លើយ)

- អើចុះ នាងណាមួយសុជាតានោះ តើពិតជាមានឈ្មោះ ថាមីគ្រុគ ដែលមកពីលើត្រូវជាគូដណ្ដឹងរបស់ប្រិក ?

- ចាំ ! នាងខ្ញុំអ្នកមីង (សុភាពនារី ១រូបទៀតដែលតាំងពីឡើងមក ឥតឆ្លើយសោះ មានវាចាយ៉ាងសុភាព)

ប្រិកឮដូច្នេះស្ទុះភ្លែត ចូលមកចាប់ដៃកញ្ញានេះ ហើយសួរថា នាងឬ ដែលឈ្មោះមីគ្រុគ ហើយមករៀនឈ្មោះសុជាតា ?

- ចាំបង ! បងមិនស្គាល់ខ្ញុំទេ ?

- ស្លាប់ហើយខ្ញុំជួបរាល់តែថ្ងៃ តែខ្ញុំមិនស្គាល់មីគ្រុគឯងសោះ (ប្រិក អរណាស់ អរទាល់តែភ្លេចខ្មាសមិត្តនារីឯទៀត) ។

- នាងអើយ ! យប់មិញប្រិកដេកឥតលក់ទេ វាសប្បាយចិត្តណាស់ ដែលនាងបានឱ្យវាស្គាល់ដូច្នេះ ដំបូងវាមិនចង់ឱ្យនាងស្គាល់វាទេ ព្រោះវាថា ខ្មាសនាងណាស់ ។

- ចាំអ្នកមីង ! នាងខ្ញុំមកនេះ គឺមកសូមលាអ្នកមីង នឹងលោកគ្រូទៅ នៅឯភ្នំពេញផ្ទះបងប្អូនវិណានេះ ដើម្បីដាក់ពាក្យសុំចូល ធ្វើគ្រូបង្រៀន (សុជា តាឆ្លើយ)

- អើ ! ទៅក៏ទៅចុះ ឱ្យសុខសប្បាយ ហើយឧស្សាហ៍សរសេរសំបុត្រ មកលេងមីងផង ជាពិសេសប្រិកនេះឯង ។

- ចាំអ្នកមីង ។

- បងប្រិក ! អូនទៅភ្នំពេញស្អែកនេះហើយ បងនៅត្រូវខំរៀនឱ្យ មែនទែន ។ ដល់កាលណាអូនបានការធ្វើហើយ អូនសុំទៅស្រុកយើងចាំអូន សរសេរសំបុត្រមកជំរាបបង ។

- បាទ ! អូនទៅចុះ តែឧស្សាហ៍សរសេរសំបុត្រមកប្រាប់បងពីសុខ ទុក្ខអូនផង (ប្រិកឆ្លើយមុខស្ងួត)

- ចាំបង ! ខ្ញុំទៅទាំងបីនាក់ ហើយនៅផ្ទះជាមួយគ្នាសូមបងកុំព្រួយ គិតដល់អូនឱ្យសោះ (សុជាតាឆ្លើយ)

- មិនអីទេ ! បើបានសុខទុក្ខយ៉ាងណា ត្រូវសរសេរមកប្រាប់បងកុំឱ្យ ខានឱ្យសោះ)

- ឱ ! ឯងទាំងបីនាក់បំរុងទៅភ្នំពេញស្អែកនេះឬ ?

- ចាំអ្នកមីង !

ដោយគេមានធុរៈជាច្រើនទៀត ដើម្បីទៅជំរាបលាមិត្តនារីដទៃទៀតផង នាងទាំងបីនាក់ក៏ជំរាបលាប្រពន្ធលោកគ្រូ សុខុមនឹងប្រិកចេញទៅ ។

ឯប្រិកវិញ រកនិយាយអ្វីមិនកើតសោះ តែគេខំសម្លឹង សុជាតាបណ្តូល ចិត្តគេឥតដាក់ភ្នែក ។

❀❀❀

## ៨

## បែកចិត្តព្រោះឃើញទ្រព្យ

រឿងរ៉ាវរបស់កញ្ញាសុជាតា បានឮសុះសាយពាសពេញទាំងអនុវិទ្យាល័យ ព្រោះគេបានឃើញប្រិកនឹងកញ្ញារូបនេះ ស្រុះស្រួលរាប់រកគ្នា ព្រមសារភាពថា ពីដើមឈ្មោះមីគ្រុគជាប្រាកដ ហើយពិតជាគូដណ្តឹងរបស់ប្រិកមែន ។ ឯប្រិកវិញកាលបើគោលបំណងបានដល់ទីដៅហើយ ! ទៅជាមិនចង់ព្រមហុចដៃទទួលទៅវិញ ។ ប្រិកខុសប្លែកពីធម្មតា កាលបើឃើញគូដណ្តឹងខ្លួនគេឡើងឡានលាចាកទៅកាន់ព្រះរាជធានី ប្រិកគ្រាន់តែមានទឹកមុខស្ងួតលើកដៃធ្វើជា សញ្ញាលាគ្នា តែប្រិកឥតធ្លាយអ្វីមួយម៉ាត់ទៀតទាល់តែសោះ ។

តើយល់យ៉ាងម៉េច ។ រឿងនេះបើយើងឆ្លុះឱ្យធ្លុះដល់បេះដូងប្រិកទៅក៏អាចដឹងថា ប្រិកឥតត្រូវការនិយាយច្រើនទៀតទេ ព្រោះថាកាលបើគេស្មោះស្ម័គ្រនឹងយើង មិនចាំបាច់និយាយច្រើននាំឱ្យគេធុញទ្រាន់ផ្ទុយទៅវិញត្រូវទុក ឱ្យចិត្តគេចេះធ្វើការវិនិច្ឆ័យទៅចុះ ។ ឃើញទេ

ប្រិកចេះគិតជ្រៅជ្រះមែន ប្រិក មិនចង់ធ្វើអ្វីឱ្យគេពុំចូលចិត្តឡើយ ព្រោះប្រិកធ្លាប់ស្តាប់គេ ធ្លាប់ទទួលសារភាពថា មកតាមរកគេ ដូច្នេះត្រូវគេចេះខ្លួនឯងនឹករឮកដល់គេវិញ ។

កាលវេលាក៏ចេះតែកន្លងទៅ ប្រិកបានប្រឡងជាប់ចូលអនុវិទ្យាល័យ ហើយតែប្រិកខានបានទទួលសំបុត្រពីស្រស់ស្រីព្រលឹង គេចំនួនពីរខែកន្លងទៅហើយ ទោះប្រិកខំសរសេរទៅសុំឱ្យគេឧស្សាហ៍សរសេរមកលេងក៏គេពុំឃើញ ហាក់ដូចជាឥតបានទទួលដំណឹងអ្វីសោះ ឬសំបុត្រមិនដល់ ។ ម្ល៉ោះហើយ ប្រិក គ្មានសង្ឃឹមទេ គ្មានសង្ឃឹមរហូតដល់លែងសរសេរទៅទៀត ដូច្នេះការទាក់ទង និងគ្នាក៏ត្រូវកាត់ត្រឹមនេះតែទឹកចិត្តគេមិនព្រមដាច់ទាល់តែសោះ ។

ឯកញ្ញាយើងវិញ កាលបើបានមកដល់ភ្នំពេញហើយ នាងត្រូវមានការ ច្រើនណាស់ដែលត្រូវប្រតិបត្តិ ម្យ៉ាងទៀតនាងបានជួបប្រទះនិងជីវិតថ្មីរបស់នាងហាក់ប្លែកក្រៃលែង ព្រោះនាងត្រូវបានគ្រួសារលោកសុជាតិគ្រប់គ្រង ។

ទៅណាមកណាសុទ្ធតែជិះឡាន មិត្តនារីនាងសុទ្ធតែកូនសេដ្ឋី សុជាតា ភ្លេចថានាងកើតនៅជ្រោះភ្នំ មានកំណើតជាខ្មែរដើមឡើយ ។ មួយថ្ងៃៗគេឥតដែលឱ្យនាងធ្វើការអ្វីទេ ។ សក់នាងដែលធ្លាប់តែកាត់ខ្លី ឥឡូវអ៊ុតយ៉ាងទាន់សម័យ ។ ក្រចកដៃធ្លាប់តែយកចុងកាំបិតតម្រឹមឥឡូវសុទ្ធតែជួលចិនសម្រួចលាបរលោងស្រិលរុយទំរអិល ។ មួយថ្ងៃៗនាងនឹងមិត្តរវល់តែប្រណាំងប្រជែង និងសោភ័ណភាពគ្នា ។ សុជាតា ពីដើមកាលនៅរៀនឯអនុវិទ្យាល័យក្រចេះ ដូចជាចេះនឹកស្រុកកំណើត នឹកឪពុកម្តាយ នឹកបងប្រិក ឥឡូវគ្មានសោះ គ្មានរហូតមិនចង់មិនចូលចិត្ត មិនចង់ប្រាប់គេថា នាងជាកូនខ្មែរលើទៀតផង ព្រោះខ្លាចក្រែងគេដៀលថាឯងកូនភ្នង ឥឡូវនាងយល់រឿងខុសថាត្រូវ រឿងអាក្រក់ថា ល្អ

ពាក្យនាងសុំចូលធ្វើការបង្រៀន មិនទាន់បានទទួលលទ្ធផលនៅឡើយទេ តែនាងដូចជាមិនទាន់ចង់ដឹងរឿងនេះសោះ ។ ពីដើមនាងបានសន្យាថា កាលណានាងបានធ្វើគ្រូបង្រៀន នាងនិងសុំផ្លាស់ទៅវិញហើយ នាងបានខំអង្វរលោកសុជាតិឱ្យសុំនាង ដើម្បីទៅព្រះរាជធានី ឬខេត្តណាមួយដែលនៅជិតទីក្រុង ។ ពីដើមនាងថាមានតែស្រុកកំណើតនាងទេ ដែលសប្បាយ ដែលផ្តល់នូវសុភមង្គលដល់នាង ឥឡូវនេះស្រុកកំណើតនាងមានសុទ្ធតែភ្នំសម្បូរណ៍ទៅដោយសត្វសាហាវ មនុស្សមិនស្អាតស្អំដូចទីក្រុងទេ នាងធុញណាស់ ទៅនៅស្រុកមិនកើត បើនៅកើតក៏អស់កិត្តិយស ព្រោះមនុស្សស្រុកលើមិនសូវយល់ខ្ពស់ទាប ។

រាល់ថ្ងៃនាងសប្បាយណាស់ សប្បាយដោយបានចំណីឆ្ងាញ់ជិះឡាន កែប-អង្គរវត្ត មើលកុន ឥឡូវរាំទៀត ។ មិត្តនារីនាងខំជួយដាស់តឿនដែរ តែនាងយល់ថាគេច្រណែននឹងនាង គេចង់ដណ្តើមនាង ។ នាងបាក់ចិត្តទៅលើគេ ហើយដោយគេមិនទាំងដឹងខ្លួនផង ព្រោះគេស្រឡាញ់រាប់អាននាង ដោយយល់ថា នាងជាមិត្តនឹងប្អូនជីដូនមួយគេ ។

តើយើងជឿបានទេ ចិត្តមនុស្សលោក ថ្ងៃនេះរាប់អាន ស្អែកថាសត្រូវ ខានស្អែកថាសង្សារ ។ គួរឱ្យអាណិតសុជាតា កញ្ញាមណ្ឌលគិរីណាស់ ។

\- - - - - - - - - - - - - - - - - -

ពីរខែកន្លងមក កញ្ញាសុជាតានឹងមិត្តនារីនាងឯទៀត ត្រូវបានរាជការ ទទួលឱ្យធ្វើគ្រូបង្រៀនដោយអនុគ្រោះ ដើម្បីលើកទឹកចិត្តខ្មែរលើ ។ តែ កញ្ញាយើងមិនព្រមទៅស្រុកទេ នាងរកលេសថាឈឺ សូមរាជការអនុញ្ញាតឱ្យ នាងបាននៅព្យាបាលរោគឯក្រុងសិន ឆ្នាំក្រោយទៀតនាងនិងសុំទៅជាមិនខាន ដូច្នេះនាងជាអ្នកគ្រូមួយរូបក្នុងព្រះរាជធានីយើង ។

យើងសូមនាំអ្នកអានក្រឡេកទៅឯក្រចេះវិញ។ ចូលកងទៅហើយ ប្រិកក៏ចូលខ្លួនទៅនៅក្នុងអនុវិទ្យាល័យដែរ ប្រិកឈប់នៅផ្ទះលោកគ្រូសុខុម ទៀតហើយ តែប្រិកនៅតែទៅមកជានិច្ច ។ មួយថ្ងៃហើយមួយថ្ងៃទៀត មួយខែហើយមួយខែទៀត ប្រិករង់ចាំសំបុត្រមិត្រគុគ ឬសុជាតា ដោយក្តីអស់សង្ឃឹម ។ ជួនជាមានពេលសំរាកឈប់បុណ្យប្រាំថ្ងៃ ប្រិកមានប្រាថ្នាចង់ទៅលេងភ្នំពេញ ដើម្បីសួររកគូដណ្តឹងគេ ព្រោះគេបានដំណឹងយ៉ាងច្បាស់ថា សុជាតាបាន ធ្វើគ្រូហើយ ។ មិនបានផ្លាស់ទៅស្រុកទេ ឥឡូវនេះនៅបង្រៀនឯក្រុង ។ ប្រិក បានទៅទាក់ទងសួរគេឯងបានស្គាល់អាស័យដ្ឋានអ្នកគ្រូសុជាតាថានៅបង្រៀនសាលា... តែប្រិកពុំដឹងថាសាលានោះនៅឯណាទេ ។ ប្រិកសង្ឃឹមថាមាត់ជាផ្លូវ ។

មួយថ្ងៃក្រោយមក ប្រិកបានមកដល់ភ្នំពេញ ដែលជារាជធានីទូលំទូលាយសម្បូរណ៍សប្បាយ រថយន្តខ្វាត់ខ្វែងឆ្លងថ្នាល់ម្តងៗប្រិកប្រហោងពោះ ស្ទើរលោះព្រលឹង តែប្រិកជាសិស្សអនុវិទ្យាល័យ ហើយក៏ជាពូជអ្នកក្លាហានទៀតផង ប្រិកឥតកោតក្រែងសោះ ។ ដើម្បីសម្រួលដំណើរគេ ប្រិកបានសួរ ប៉ូលិសម្នាក់ដែលយាមថ្នល់ថា :

- លោក ! សូមអភ័យទោស តើសាលា.... នៅឯណា ?

- បាទ ! ក្រោយដែលបានសំដែងការគួរសមរួច ក៏ឆ្លើយថា : សាលា នោះនៅក្នុងសង្កាត់លេខ ៤ ។

- ចុះលោកអាចឱ្យអ្នកណាជូនខ្ញុំទៅសាលារៀននោះផងបានឬទេ ?

- បាទ ! ដូច្នេះសូមប្អូនចាំមួយភ្លែត ។

- ស៊ីក្លូ ! (ប៉ូលិសនោះហៅស៊ីក្លូ)

- ពូឯងនាំប្អូននេះទៅដល់សាលា.... នៅ.... ឮទេ ?

- បាទលោក ! (អ្នកស៊ីក្លូឆ្លើយ)

ក្រោយដែលថ្លែងអំណរគុណប៉ូលិសរួច យុវជនយើងក៏ឡើងស៊ីក្លូទៅ ។ មិនយូរប៉ុន្មានប្រិកទៅដល់សាលា តែអកុសលហួសម៉ោង ៥ ល្ងាចទៅហើយ សាលាបិទទ្វារជិតសិស្សទៅផ្ទះអស់ ប្រិកដើរចូលទៅក្នុងសាលា ហើយបានជួបនឹងកម្មករម្នាក់ ។ ប្រិកបានសួរយកការណ៍បានសព្វគ្រប់ថា អ្នកគ្រូបណ្តូលចិត្ត គេពិតជាបង្រៀនសាលានេះមែន ។

យប់នេះ ប្រិកគ្មានបរិភោគទេ ប្រិកទិញនំប៉័ងមួយមកជំនួសបាយ ហើយទទួលទានទឹកម៉ាស៊ីន ។ មួយយប់ទល់ភ្លឺ ប្រិក ឥតគេងទេ ប្រិកបានសុំរានហាលសាលាសំរាកកាយ ។

ស្អែកឡើងមកឈរនៅក្រៅរបងសាលា ដើម្បីចាំមើល សុជាតា បណ្តូលចិត្ត ។ ម៉ោង ៧ ទៅហើយមិនទាន់ឃើញទៀត..... ។

- សុជាតា ! សុជាតា ! បងមករកអូនណា៎ ! (ប្រិក ស្រែកហៅ កាលបើឃើញសុភាពនារីមួយរូប ជិះឡានជិតបុរស អ្នកបើកចូលមក)

- សុជាតាឥតឆ្លើយទេ គ្រាន់តែងាក ហើយធ្វើព្រងើយ

- ហ៎ ! អ្នកណាហៅអ្នកគ្រូ (អ្នកបើករថយន្តសួរ)

- សុជាតាធ្វើព្រងើយហាក់មិនឮ

បន្ទាប់មក ក្រោយដែលចុះពីឡានភ្លាម អ្នកគ្រូសុជាតាក៏ដើរចូលក្នុង ថ្នាក់បាត់ទៅ ។ រថយន្តក៏ត្រឡប់ទៅវិញបាត់ដែរ ។ ប្រិកកាលបើឃើញដូច្នេះ ក៏ដើរតាមរ៉ុយឥតកោតញញើតអ្វីឡើយ លុះដល់ផ្លូវដែលអ្នកគ្រូសុជាតាចូល ប្រិកញញឹមហើយពោលថា :

- អូនសុជាតា ! អូនរឹតតែស្អាតជាងពីដើមមែនទេ ? (ប្រិកសួរ ដោយគ្មានគិតថា មានសិស្សនៅជិតខ្លួនគេច្រើនឡើយ)

- អ៊ូ ! បងប្រិកទេ ! បងមកធ្វើអ្វី ? មករកអ្នកណា ? ហើយមក ពីអង្កាល ?

- បងមករកអូនណា បងមកដល់ពីម្សិលមិញ ហើយសុំគេសំរាកត្រង់ ខាងមុខនេះ (ប្រិកចង្អុលទៅរានហាលមុខថ្នាក់អ្នកគ្រូយើង)

- ដូច្នេះបងប្រិកទៅដើរលេងសិនទៅ ចាំដល់ម៉ោង ចាំ... ទេ ! ទេ ! ទៅមិនបានទេ ព្រោះខ្ញុំនៅជាមួយនិងគេ សុំផ្ទះគេនៅ ខ្ញុំមិនហ៊ាននាំបងទៅទេ ដូច្នេះបងមានការអ្វីនិយាយមកឥឡូវនេះឱ្យហើយចុះមិនអីទេ ចាំខ្ញុំសុំលោក ចាងហ្វាយ ១ ម៉ោង ឬ ២ ម៉ោង (អ្នកគ្រូគូដណ្តឹងកម្លោះយើងពោល)

- អូនសុជាតា ! ហេតុអ្វីក៏អូនមិនឱ្យដំណឹងទៅដល់បងដូច្នេះ (ប្រិក សួរទាំងទឹកមុខស្ងួត)

- ចាំបង ! អូនជាប់រវល់ច្រើនពេក ហើយភ្លេចសរសេរទៅបងយើង ទៅ (អ្នកគ្រូឆ្លើយញញឹមៗ)

- អូន ! ភ្លេចពាក្យសន្យាហើយ បានជាមិនសុំផ្លាស់ទៅស្រុកយើង ?

- បងប្រិក ! អូនមិនទៅទេ ព្រោះអូនមិនចេះរស់នៅស្រុកឥតកុន មើល ឥតមានការស៊ីវិល័យសោះដូច្នេះទេ ?

- ដូច្នេះអូនបំភ្លេចបងចោលហើយមែនទេ ?

- ចាំបង ! អូនមិនមែនមានចិត្តដូច្នេះទេ តែអូនចង់រស់នៅឱ្យបាន សុខស្រួលជាងមុនៗទេតើ ។

- បងមិនជឿអូនទេ ? អូនបានសន្យាថា កាលណាអូនបានធ្វើគ្រូ បង្រៀន អូននិងទៅបំបើកភ្នែកបងប្អូនយើងឯស្រុកភ្នំ ឱ្យបើកទាន់សម័យនឹងគេ ឥឡូវនេះគំនិតទាំងនេះ អូនបានលះបង់អស់ទៅហើយ ។

- បង ! បងប្រិក និយាយលាក់បាំងអ្វី អូនមិននិយាយការពិតប្រាប់ បងទេនាំឱ្យបងព្រួយចិត្ត តែបើបងចោទអូនដូច្នេះមកហើយ អូនក៏ត្រូវតែនិយាយការពិតប្រាប់បងដែរ (អ្នកគ្រូមានវាចាយ៉ាងស្រងូតស្រងាត់ ឯប្រិក អង្គុយស្ងៀមកាន់កញ្ចប់ បង្វិចមួយឥតហ៊ានដាក់ធ្វើ ភ្នែកភ្លឹសៗ) ។

- បងប្រិក ! អូនសូមបងឈប់ប្រកាន់ពាក្យថា អូនជាគូដណ្ដឹងទៅវិញចុះ ចាប់ពីថ្ងៃនេះទៅ ព្រោះអូនខុសហើយ ខុសដោយពុំបានគោរពតាម គោលបំណងយើង ។

- បងក៏យល់ដូច្នេះដែរ តែបងមកនេះ គឺមកបញ្ជាក់អូនឱ្យច្បាស់ ដូច្នេះទេតើ ឥឡូវបើអូនដាច់អាល័យពីបង ក៏បងមិនហ៊ានបង្ខំចិត្តអូនដែរ ព្រោះ អូនជានារីដែលមានឋានៈខ្ពង់ខ្ពស់ម្នាក់ទៅហើយ តែមុននឹងលាអូនទៅវិញ បងចង់ដឹងថា តើអូនមានប្ដីហើយឬនៅ ?

- នៅទេបង !

- ចុះអ្នកណាជូនឡានអូនអម្បាញ់មិញ ?

- បងប្អូនវិណា ដែលជាមិត្តអូន ហើយគេបានឱ្យផ្ទះអូនសំណាក់ទៀត ផងនោះ ។

- ហេតុអ្វីក៏អូនមិននាំបងទៅលេងផ្ទះ ដែលអូនសំណាក់អាស្រ័យ (ប្រិកសួរមកទៀត ទាំងអស់សង្ឃឹម ព្រោះគេនឹកថា យប់នេះត្រូវដេករានហាលនេះទៀត ហើយខំលេបទំប៉ុងផឹកទឹកម៉ាស៊ីនទៀតមិនខាន)

- អូនខ្លាចខ្មាសគ (សុជាតានិយាយត្រង់)

- អូនខ្លាចខ្មាសគេ ព្រោះឃើញបងក្រមែនទេ ? (ប្រិក បញ្ជាក់)

- ដូច្នេះក៏ម្យ៉ាង ឯម្យ៉ាងដែលធំទៅទៀត ត្រង់បងនឹងខ្ញុំ ព្រោះខ្ញុំខ្លាច បងអួតប្រាប់គេថា បងជាគូដណ្ដឹងនឹងខ្ញុំ ព្រោះខ្ញុំជាអ្នកគ្រូទៅហើយឯបងៗជាសិស្សនៅឡើយ ពិសេសទៅទៀត ខ្ញុំព្រួដឹងណឹងថាលោកដែលបើកឡានអម្បាញ់មិញនេះ គេមានប្រាថ្នាចង់ដណ្ដឹងខ្ញុំទៀតផង ។

- ដូច្នេះបងមិនរំខានអូនទេ ? ហើយបងក៏ស្គាល់ចិត្តអូនដែរ ហើយអាណិតអូន ស្រឡាញ់អូន ចង់ឱ្យតែអូនបានសុខបានខ្ពង់ខ្ពស់ ។ ឯចំណែកបង វិញធ្លាប់មានប៉ុណ្ណា ក៏ឱ្យវានៅប៉ុណ្ណោះទៅចុះ ។ ដូច្នេះបងសូមលាអ្នកគ្រូសិន ហើយសូមឱ្យអ្នកគ្រូបានសេចក្ដីសុខចុះ (ប្រិកបំរុងចេញទៅ)

- ឈប់បង ! អូនក៏ពុំមែនដាច់ចិត្តពីបងឱ្យស្រឡះដែរ តែអូនចង់ផ្សង តាមវាសនាទៅមើល តើបានដូចបំណងឬទេ ? តើយប់នេះបងទៅសំណាក់ឯណា ? ហើយត្រឡប់ទៅស្រុកវិញថ្ងៃណា ?

- មិនអីទេអ្នកគ្រូ ! ខ្ញុំសូមអរគុណហើយ ដែលចេះមានចិត្តសួរខ្ញុំនេះ ។ ខ្ញុំនិងត្រូវត្រឡប់ទៅវិញស្អែកព្រឹកនេះហើយ ។

- ដូច្នេះបងយក ២០ រៀលនេះទៅចុះ គ្រាន់ជាសោហ៊ុយ (អ្នកគ្រូ ដកប្រាក់ពីរយឱ្យទៅប្រិក)

- ទេអ្នកគ្រូ ! ខ្ញុំមិនហ៊ានទទួលទេ សូមអ្នកគ្រូទុកចាយចុះ ឯចំណែក ខ្ញុំ ខ្ញុំមានប្រាក់ខ្លះដែរ ល្មមត្រឡប់ទៅវិញបាន ។

ប្រិកតូចចិត្តណាស់ តែប្រិកនៅតែមានសតិរឹងប៉ឹងដរាប។ មិនស្ដាយទេមនុស្ស ប្រិកស្ដាយតែគេគិតខុស ស្ដាយតែចិត្តខំស្រឡាញ់គេ ។ ប្រិកដើរ ចេញពីសាលាដោយក្ដីសោកសៅក្រៃលែង ។

ឯអ្នកគ្រូយើងវិញ កាលបើឃើញប្រិកឃ្លាតចេញទៅ ទឹកភ្នែកក៏ធ្លាក់ ច្រោកមកលើថ្ពាល់ដ៏ផូរផង់ ដែលគួរឱ្យស្នេហ៍ជាពន់ពេក ព្រោះដូចជាពុំទាន់ ដាច់ចិត្ត តែធ្វើដូចម្ដេចបើចិត្តមានឯណោះខ្លាំងជាង ។

## ៩

## ចិត្តស្រីយ៉ាងណា

ក្រោយដែលប្រិកបានយល់ចិត្តគូដណ្តឹងគេយ៉ាងច្បាស់ហើយ ប្រិកក៏ត្រឡប់ទៅរៀនសូត្រជាធម្មតាវិញ ។ សព្វថ្ងៃនេះ ចិត្តប្រិកបានរេជាច្រើនជំពូក ប្រិករៀនថយជាងខែមុនៗ ព្រោះប្រិកចេះតែយល់ថា ការសិក្សារបស់គេឥឡូវនេះ គ្មានខ្លឹមសារទៀតទេ ។ បើគេដឹងថាសុជាតាមានចិត្តបែកបែរពុំគោរពតាម ពាក្យសន្យាតាំងពីដើមមក ម្ល៉េះគេមិនមកចោលស្រុក ចោលអ្នកមានគុណ ដូច្នោះទេ តែមានចិត្តមួយមកដោះស្រាយថា ពិតមែនតែមិនបានជួបអ្នកគ្រូ សុជាតា តែគេបានចេះចំណេះស្គាល់អារ្យធម៌នៃប្រទេសដូចគេដូចឯងដែរ ។ ប្រិកបានទៅពិគ្រោះរឿងគេនេះ នឹងលោកគ្រូសុខុមជាញឹកញាប់ ព្រោះគេចង់ឈប់រៀន ដើម្បីត្រឡប់ទៅស្រុកកំណើតប្រកបរបរអាជីវកម្មដូចបងប្អូន តែលោកគ្រូសុខុមបានពន្យល់ ទាល់តែប្រិកសុខចិត្តតស៊ូរៀនសូត្រទៅទៀត ។

យើងសូមនាំមតិអ្នកអាន បែរមកមើលសកម្មភាពនៃជីវិតអ្នកគ្រូ សុជាតា ឯព្រះរាជធានីឯណោះវិញ ។ អ្នកគ្រូយើងក្រោយ ដែលសំដែងចិត្តថ្លើមលះបង់គូដណ្តឹងគេមកចិត្តគេពុំមែនស្ងប់ស្ងៀមទៅតាមជំនោរនៃធម្មជាតិទេ។ សុជាតាអ្នកគ្រូខ្មែរលើរមែងមានសតិសម្បជញ្ញៈរំលឹកដល់រឿងចាស់ៗដែល កន្លងរួចមកហើយជាដរាប ។ ការទាក់ទងនូវផ្លូវចិត្តរវាងអ្នកគ្រូសុជាតានឹងកម្លោះសុជាតិ បានជ្រួតជ្រាបដល់វិញ្ញាណប្អូនជីដូនមួយសុជាតិ ហើយដែលចាស់ៗ គ្រោងទុកជាគូអនាគត ។

កាលបើបានឃើញសុជាតិ មានការទាក់ទងកាន់តែខ្លាំងឡើងៗនឹង អ្នកគ្រូសុជាតា ដែលជាហេតុនាំសុជាតិខូចការសិក្សាមាតាសុជាតិបានរៀបចំពិធីមួយ ដើម្បីផ្សំផ្គុំកញ្ញាវិណានឹងសុជាតិ នៅចំពោះមុខអ្នកគ្រូសុជាតា ។ ការរៀបចំពិធីនេះមិនមែនត្រឹមតែជាកិច្ចភ្ជាប់ពាក្យនឹងឱ្យចាស់ទុំដឹងឮប៉ុណ្ណោះទេ ថែមទាំងបានធ្វើឱ្យសុជាតាផុតក្តីសង្ឃឹមខ្មាសមិត្តរាប់អាន ។ ម្យ៉ាងទៀតបាន បំបាក់មុខសុជាតិឱ្យខ្មាសអៀន នឹងអ្នកគ្រូសុជាតា ម្ល៉ោះហើយពីរនាក់នេះ កាលដើមទៅណាមកណាគេរមែងបបួលគ្នាដើរលេងជាមួយគ្នា ឥឡូវនេះគេឥតឱ្យជួបមុខគ្នាទេ បើម្នាក់នៅមុខ ម្នាក់ទៀតត្រូវនៅឯផ្ទះបាយ ។

មួយខែកន្លងមកទៀត អ្នកគ្រូសុជាតាហាក់មានចិត្តធុញថប់នឹងការរស់នៅក្នុងក្រុង ព្រោះបំណងផុតសង្ឃឹម ។ ម្ចាស់ផ្ទះគេឥតដែលធ្វើអ្វី ឬចោល ឬកដែលជាហេតុនាំឱ្យអ្នកគ្រូយើងព្រួយឡើយ ។ រាល់ថ្ងៃក្រោយពេលសំរាក អ្នកគ្រូសុជាតាតែងតែខិតខំជួយធ្វើការផ្ទះដូចធម្មតា ។ វិណាមិត្តល្អរបស់ សុជាតា ក៏ឥតដែលសំដែងចិត្តថ្លើមឱ្យមិត្តគេសំគាល់ថាយ៉ាងណាៗដែរ ។ កាល បើឃើញគេធ្វើល្អយ៉ាងស្មោះចំពោះលើខ្លួនដូច្នោះ អ្នកគ្រូយើងចេះតែនឹកអៀន នឹកតូចចិត្តខ្មាសខ្លួនឯង ។

យប់នេះព្រះច័ន្ទនៅលើមេឃ មានរង្វង់មូលក្រឡង់គួរជាទីគយគន់ អ្នកគ្រូសុជាតាឥតចង់ចូលនិទ្រាទេ ព្រោះគេបានរំឭកនឹកឃើញសព្វគ្រប់ទាំង អស់នូវហេតុការណ៍ទាំងឡាយដែលកន្លងផុតទៅហើយ ។ វិប្បដិសារីរបស់អ្នកគ្រូជាប់ជំពាក់ទៅលើរឿងផ្ទាល់ខ្លួន ជាងរឿងដទៃទៀត ម្ល៉ោះហើយយូរៗគេឮ សូរកញ្ញាយើងដកដង្ហើមធំម្តង ។ ខ្សែជីវិតបានមកបង្ខំដួងចិត្តអ្នកគ្រូ ឱ្យចេះនឹក ដល់ប្រិកជាគូដណ្តឹង ។ អ្នកគ្រូក្រមុំនឹកស្តាយក្រោយជាច្រើន ដែលបានធ្វើអំពើ មិនគប្បីចំពោះប្រិក ដែលជាកម្លោះមានកំណើតនៅជ្រោះភ្នំដូចគ្នាហើយថែមទាំងមានភក្តីភាពយ៉ាងស្មោះស្ម័គ្រជាទីបំផុតចំពោះនាង ។ នាងត្រូវរំលឹកនឹកឃើញថា ក្នុងលោកនេះគ្មានអ្វីប្រសើរជាងការ ដែលមានចិត្តស្មោះចំពោះគ្នាទៅ វិញទៅមកនោះទេ ដូច្នោះក្នុងជីវិតនាង ដែលកើតឡើងប៉ុណ្ណោះ គ្មានអ្នកណាស្មោះចំពោះនាងជាងបងប្រិកឡើយ ទោះនាងមានបង្គាប់ឱ្យធ្វើអ្វីក៏គ្នាធ្វើតាមទាំងអស់ តាមតាំងពីភ្នំរហូតដល់ខេត្ត តាំងពីមិនចេះអក្សរមួយអង្គ រហូតចេះប្រឡងចូលវិទ្យាល័យនឹងគេជាប់ទៀតនិយាយឱ្យអស់ទៅទៀត តាមតាំងពីមិនចេះស្លៀកខោរហូតដល់ស្រាតខោដោះអាវមិនកើត តើអំពើនេះសរឱ្យឃើញថា ប្រិកពិតជាបុរសគ្រប់

លក្ខណៈឬទេ ? ស្តាយណាស់ ស្តាយកាលដែល បងប្រិកមកតាមដល់ព្រះរាជធានី តាមរកឯងរហូតដល់សាលាដេកដោយ សំយាបថ្នាក់រៀន ដើម្បីស្វែងរកឯង មិនគួរឡើយចិត្តកាលណោះអីក៏អប្រិយ៍ ម្ល៉េះ ។ នឹក។ទៅដូចជាអាណិតបងប្រិក ។

អាណិតបងប្រិកចង់តែរត់ទៅសូមទោសបងប្រិក សូមកុំឱ្យគេប្រកាន់ទោសចាប់ថ្នាក់ពីអំពើទាំងឡាយដែលគេបាន ធ្វើកន្លងហួសទៅហើយនោះ បើសិនណាជានៅជិតគ្នា ។ គិត។ទៅ បងប្រិកក៏មិនមែនអន់ជាងបងសុជាតិដែរ ថ្វីបើបងប្រិកកើតនៅស្រុកភ្នំ ខ្វះខាតទ្រព្យសម្បត្តិ តែចិត្តថ្លើមមនុស្សធម៌ស្មោះត្រង់ បងប្រិកមិនចាញ់អ្នកណាទេក្នុងលោកនេះ។ បុរសក្នុងក្រុងមានចិត្តសាវ៉ា ប្រៀបបាននឹងចកកណ្តាលទន្លេ រសាត់តាមអំពើចិត្ត ឯបងប្រិកវិញ ចិត្តគេនឹងថ្កល់មិនចេះនិយាយ ហើយបំភ្លេចចោលទៅវិញឡើយ ។ បន្តិចទៀតបងប្រិកមុខជាប្រឡងជាប់ដូចគ្នានឹងឯងដែរ ហើយមុខជាបានមុខការអ្វីដូចគេដូចឯងមិនខាន ដូច្នេះតើទៅរកឯណាទៀតឱ្យបានហួសពីបងប្រិកទៅទៀត ។ នឹកទៅដូចជាស្តាយបងប្រិកណាស់ មិនគួរធ្វើឱ្យចំណងដែលខំចងតាំងពីបួនឆ្នាំ ដែលកន្លងមកហើយមកដាច់ស្រឡះឥតស្រណោះដូច្នេះសោះ ។ បងប្រិកក៏មានកំណើតនៅជើងភ្នំដូចគ្នានឹងឯងដែរ ម្តេចចិត្តគេខែងរែងជាងឯង មានការស្មោះត្រង់ល្មម្ល៉េះ ចុះឯងក៏ខុសគេប្រញាប់ ភ្លេចម្ល៉េះនូវពាក្យសន្យា ។ ខ្លួនឯងទេតើ ដែលសន្យានឹងគេ ថាមិនលះបង់គេទេ កាលណាឯងបានការធ្វើនឹងត្រឡប់ទៅស្រុកកំណើត រៀបការជាមួយគេ ឥឡូវនេះខ្លួនឯងសោះ ដែលក្បត់ចិត្តគេ ក្បត់ការស្មោះត្រង់នឹងគេ ភ្លេចពាក្យសច្ចៈដែលបានសន្យានឹងគ្នា ហ៊ឺ ! អាណិតបង ប្រិកណាស់ មិនដឹងជាបងខ្លោចផ្សានឹងអំពើដែលអូនបានប្រព្រឹត្តកន្លងទៅហើយនោះយ៉ាងណាទៅ ។ បងប្រិក ! នៅចំពោះមុខព្រះច័ន្ទយប់នេះ (អ្នកគ្រូយើងងើបមើលដួងច័ន្ទ មាត់នាងបានបន្លឺពាក្យទាំងរវើរវាយ) អូនសូមលាសច្ចាសារជាថ្មី ថានឹងឈប់មានគំនិតឬចិត្តពុតអាក្រក់ដូចមុនទៀតហើយ អូនសន្យាថា នឹងសូមរាជការត្រឡប់ទៅស្រុកយើងរង់ចាំបងលុះអវសានជីវិតមិនខាន។ អូនឈប់ប្រកាន់ចិត្ត ពុំគប្បីដូច្នោះទៀតហើយសូមព្រលឹងនៃបងមកទទួលយកអូនទៅនៅជាមួយបងផង ។ សូមព្រះច័ន្ទដ៏ល្អនៃរាត្រីនេះ ទទួលពាក្យសច្ចៈនេះទុក ជាភស្តុតាងតំណាងបងផង ព្រោះយើងទាំងពីរនៅឆ្ងាយពីគ្នាណាស់ ពុំអាចរត់ ទៅរកគ្នាបានទាន់ចិត្តឡើយ ។

- នែ៎ ! សុជាតា ! ឯងមិនទាន់ចូលគេងទេ ម៉ោងជាងពីរទៅហើយ ? ល្មមចូលគេងហើយ កុំនៅយូរពេកស្អែកធ្វើការផង។

កញ្ញាយើងភ្ញាក់ព្រើត ព្រោះអង្គុយម្នាក់ឯងសោះ ម្តេចមានអ្នកណា មកនៅជិត ក៏ឆ្លើយទាំងរវើរវាយថា :

- គ្នាមិនទាន់ងងុយទេវិណា ? ឯងគេងមុនគ្នាចុះ

- ម៉ោងជាងពីរហើយ ឯងមិនងងុយគេងទៀត ?

- ម៉ោងជាងពីរហើយ យីយប់នេះម៉ោងអីក៏ឆាប់ម្ល៉េះ ?

- ចុះឯងនិយាយស្ទីអម្បាញ់មិញម្នាក់ឯង ឮរអ៊ូរអ៊ូ ? (កញ្ញាវិណា សួរ)

- យើងឥតនិយាយអ្វីទេ គ្នាឃើញព្រះច័ន្ទមានរង្វង់ នឹងពន្លឺល្អគ្នាចង់ តែនិយាយលេងជាមួយ ។

- ឯងចង់និយាយជាមួយព្រះច័ន្ទ ? ឯងចង់មិនស្រួលហើយឬ ?

- ទេ យើងស្រឡាញ់ព្រះច័ន្ទណាស់យប់នេះ ហើយចង់នៅអង្គុយ លេងទឹកនោះជាមួយព្រះច័ន្ទលុះអស់ពន្លឺនេះ ។

- គ្នាដូចជាហួសចិត្តហើយ បើឯងនិយាយដូច្នោះ (វិណា អស់ សំណើច)

- ឯងទៅគេងវិញចុះ ទុកឱ្យគ្នាអង្គុយលេងបន្តិចទៀតសិនចុះ មិនអី ទេ (សុជាតានិយាយដោយមុខស្ងួត)

-ឯងព្រួយចិត្តរឿងស្អីជាតា ឯងប្រាប់គ្នាផងបានទេហើយបើរឿង នោះគ្នាអាចជួយបាន គ្នាធានាជួយឯង ។

- យើងឥតមានរឿងអ្វីទេ ហើយក៏មិនដឹងប្រាប់អ្វីដល់ឯងដែរ ។

- ឱ្យតែឯងប្រាប់យើង យើងជួយវិនិច្ឆ័យរឿងនេះដល់ឯង ។

- យើងឥតព្រួយអ្វីទាល់តែសោះ ការពិតយើងនឹកទៅដល់ស្រុកកំណើតយើង និងឪពុកម្តាយបងប្អូនយើង ដែលយើងខានបានទៅលេងជាច្រើន ឆ្នាំកន្លងទៅហើយ ។

- ដូច្នេះឯងមិនត្រូវព្រួយពេកទេ ដល់វ៉ាកងនេះឯងអាចទៅលេងបាន ហើយ ។

ក្រោយដែលនិយាយគ្នា លេងបន្តិចបន្តួចរួចហើយ កញ្ញា វិណាក៏ចូលនិទ្រាវិញទៅ ទុកឱ្យអ្នកគ្រូមានទុក្ខព្រួយនៅម្នាក់ឯងតទៅ ទៀត

## ១០

## បានជួបព្រោះមានបំណាច

ក្រោយដែលអ្នកគ្រូក្រមុំ បានរំឭកនឹកឃើញឡើងវិញនូវកំហុសរបស់ ខ្លួន ដែលបានធ្វើកន្លងហួសទៅហើយចំពោះប្រិកគូដណ្ដឹងមក សេចក្ដីទុក្ខពុំព្រមរសាយចេញពីទ្រូងនាងឡើយ ។ ចិត្តនាងតែងតែព្រួយបារម្ភខ្លាចក្រែងចិត្តគូដណ្ដឹងនាង គេបែកបែរឈប់រាប់រកនាងតទៅទៀត ។ ម្យ៉ាងទៀតមិនដឹងថា បង ប្រិក យកដំណឹងទៅផ្សាយពាសពេញភូមិថា ឯងបានការធ្វើហើយលះបង់ គេចោលដោយឥតមេត្តាទៅហើយក៏មិនដឹង នឹកទៅដូចជាខ្មាស លោកគ្រូសុខុម នឹងមិត្តដទៃទៀត ដែលបានដឹងថាឯងភ្លេចកំនើតនិយាយអ្វីមិនទៀតទាត់ ។ រាល់យប់រាល់ថ្ងៃ អ្នកគ្រូ សុជាតាគេងមិនលក់អង្គុយមិនស្រណុកទេ ចិត្តនាងពោរពេញទៅដោយទុក្ខព្រួយ ។

ថ្ងៃខែចេះតែកន្លងទៅ ឥតដែលត្រឡប់ថយក្រោយវិញឡើយ វ៉ាកង ធំក៏មកដល់ អ្នកគ្រូយើងក៏បានលាចាកព្រះរាជធានីឆ្ពោះទៅកាន់ទីរួមខេត្ត ក្រចេះ ដើម្បីធ្វើដំណើរទៅភូមិពូក្រិកលើ ។ តាមផ្លូវចិត្តនាងរមែងរិះរេជាច្រើនរយជំពូក ភ្នែកនាងរំពៃគយគន់ស្រុក ភូមិទាំងឡាយ ដែលនៅតាមដងផ្លូវយូរៗ នាងគ្រុគដកដង្ហើមធំម្ដង ដើម្បីបន្ធូរដើមទ្រូងដែលស្ទះទៅដោយខ្យល់ធុញថប់ តើនាងត្រូវទៅសំណាក់នៅផ្ទះអ្នកណា ? បើទៅផ្ទះលោកគ្រូសុខុម មុខជាជួប បងប្រិកមិនខាន ។ ទេ ! បងប្រិកឥតនៅផ្ទះ លោកគ្រូសុខុមទេ ព្រោះសព្វថ្ងៃ នេះបងប្រិកច្បាស់ជាទៅនៅសាលាហើយ ។

- ហ៊ឺ ! ដូចជាខ្មាសបងប្រិកដែរ មិនគួរហ៊ានមកឱ្យគេឃើញមុខសោះ គួរតែទៅឱ្យបាត់កុំឱ្យជួបមុខគេ ព្រោះឯងភ្លេចការស្មោះត្រង់និយាយមិនទៀតទាត់មែន ។ បងប្រិកឥតរៀនទេ ព្រោះវ៉ាកង ដូច្នេះច្បាស់ជានៅផ្ទះលោកគ្រូ សុខុមហើយ ។ តែណ្ហើយទោះមានហេតុការណ៍អ្វីក៏ដោយក៏មិនត្រូវខ្លាចដែរ ឯងខុស ត្រូវមានសេចក្ដីក្លាហានទទួលខុស ។

រថយន្តបោលឥតខ្ជិល បានជូនអ្នកដំណើរមួយចំនួនរួមទាំងអ្នកគ្រូ ក្រមុំ យើង មកដល់ទីរួមខេត្តក្រចេះដោយសុវត្ថិភាព ។

អ្នកក្រុងក្រចេះឥតស្គាល់ថាកញ្ញាដ៏ស្រស់នេះ មានកំណើតជាខ្មែរលើទេ ព្រោះរូបសម្បត្តិនាងបានទាញប្រស្រៃភ្នែកព្រានកម្លោះឱ្យតាមមើលសឹងមិនដកភ្នែក ។ លុះមកដល់ផ្ទះ លោកគ្រូសុខុម គាប់ជួនពេលនោះលោកគ្រូនៅផ្ទះឥតទៅណាឡើយ ។

- ជំរាបសួរលោកគ្រូ ! (កញ្ញាស្រស់រូបល្អដាក់វ៉ាលីសចុះ ហើយ សំដែងការគួរសម)

- អឺ ! បាទ ! លើកដៃថ្វាយព្រះ (លោកគ្រូឧទានឡើង ដោយភ្ញាក់)

- អ្នកអញ្ជើញទៅណា ? លោកគ្រូសុខុមសុខសប្បាយទេ ?

- បាទនាង ! គេហ៍នៅខាងក្នុង ។ នាងនៅឯណា ?

- ចាំ ! លោកគ្រូមិនស្គាល់នាងខ្ញុំទេ ?

- មែនហ្ន៎ ! ខ្ញុំ... ខ្ញុំដូចជាប្រហែលៗនាងដែរ តើនៅឯណា ធ្លាប់រៀន នៅសាលាក្រចេះនេះដែរឬទេ ?

- ចាំ ! លោកគ្រូ ! ខ្ញុំធ្លាប់រៀននៅសាលាក្រចេះនេះ ។

ដោយបានឮពាក្យឆ្លងឆ្លើយគ្នា ប្រពន្ធលោកគ្រូសុខុមក៏ចេញពីក្នុងផ្ទះ ហើយសួរថា :

- នាងមកដល់ពីអង្កាល ?

- ជំរាបសួរអ្នកបង ! (អ្នកគ្រូយើងសំដែងការគួរសមភ្លាម)

- ចាំវ៉ា ! នាងនេះដែលប្រិកគេហៅថាឈ្មោះ គ្រុគនោះ ឯងភ្លេចគ្នាភ្លាមទៅហើយ (ប្រពន្ធលោកគ្រូសុខុមប្រាប់ប្តីគាត់ ដែលធ្វើឱ្យនាងគ្រូខ្មែរលើ យើងបុកពោះដកដង្ហើមសឹងមិនដល់គ្នា)

- អឺអើ ! ឯងភ្លេចឱ្យឈឹង យីទៅបាត់តែងជិត ១ ឆ្នាំ ស្អាតហើយ ស្រស់ទៀត ឯងស្មានតែមកពីណា មើលទៅស្មានតែអ្នកភ្នំពេញ ។

- ចុះឯងបានធ្វើការហើយឬនៅទេ ? (លោកគ្រូសុខុម ធ្វើជាសួរមក ទៀតដើម្បីបញ្ជាក់)

- ចាំ ! លោកគ្រូ ! នាងខ្ញុំបានចូលធ្វើគ្រូបង្រៀនហើយ សព្វថ្ងៃនេះ នៅភ្នំពេញ ។

- ឱមែន ! ប្រិកគេមកប្រាប់ខ្ញុំម្តងដែរ ថានាងបានចូលធ្វើគ្រូហើយ ។ ឥឡូវនេះនាងបានជួបប្រិកហើយឬនៅ ? (លោក គ្រូសុខុមសួរ)

- ចាំលោកគ្រូ ! ឥតទាន់បានជួបទេ (អ្នកគ្រូយើងឆ្លើយដោយស្រងូត ស្រងាត់)

- នាង ! តើនាងឈ្មោះអ្វី ខ្ញុំដូចជាភ្លេចទៅហើយ នៅចាំតែឈ្មោះ ដើមមីគ្រុគ (ប្រពន្ធលោកគ្រូសុខុមសួរ)

- ចាំអ្នកបង ! ខ្ញុំឈ្មោះសុជាតា

- ឱមែន ! សុជាតា ឥឡូវនេះនាងបានធ្វើគ្រូហើយមែនទេ ដូច្នេះខ្ញុំ ត្រូវហៅថា អ្នកគ្រូៗ ។

- ចាំអ្នកបង ! មិនបាច់ហៅនាងខ្ញុំថា អ្នកគ្រូៗទេ សូមហៅតែឈ្មោះ ៗទៅបានហើយ ។

- ចុះនាងមកដល់ពីថ្ងៃណា (លោកគ្រូសុខុមសួរ)

- ចាំលោកគ្រូ ! នាងខ្ញុំទើបមកដល់

- ដូច្នេះមិនទាន់បាយទឹកទេ មែនទេ ?

- ចាំលោកគ្រូ ខ្ញុំបានទទួលទានខ្លះហើយមកតាមផ្លូវ នាងខ្ញុំមិនឃ្លាន ទេ ។

- ដូច្នេះទៅក្នុងរកផ្លាស់សំពត់អាវទៅ ឬក៏ទៅឯណាទៀត (ប្រពន្ធ លោកគ្រូសុខុមសួរដោយស្មោះត្រង់)

- ចាំ ! ខ្ញុំមកសុំកបងសំណាក់ទីនេះ ១ថ្ងៃ ២ថ្ងៃ ដើម្បីធ្វើដំណើរទៅ ស្រុកកំណើត ។

- ដូច្នេះទៅក្នុងទៅរកងូតទឹកនឹងអាលនឹងញ៉ាំបាយ ។

- ចាំអ្នកបង ! លោកគ្រូ ។

ប្រពន្ធលោកគ្រូសុខុមក៏នាំអ្នកគ្រូសុជាតាទៅក្នុងបាត់ទៅទុកឱ្យលោកគ្រូយើងសរសើរពីរូបសម្បត្តិអ្នកគ្រូយើងនេះមិនដាច់ពីក្នុងពោះមួយស្របក់ក្រោយមក អ្នកគ្រូយើងចេញមកវិញក្រោយដែលងូត ទឹកស្រស់ស្រូបចំណីអាហារបន្តិចបន្តួច ។

- នាង ! មានដែលជួបប្រិកទេ ? (លោកគ្រូសុខុមផ្តើម សួរ)

- ចាំលោកគ្រូ ! កាលពីខែ វិច្ឆិកា ឆ្នាំចាស់ បងប្រិកបានទៅរកនាង ខ្ញុំឯសាលាម្តង ។

- ក្រោយមកឥតដែលបានជួបទៀតទេ ? (លោកគ្រូ បញ្ជាក់សួរ)

- ចាំ ឥតដែលបានជួបទៀតទេ ។

-ដូច្នេះប្រិកវាឥតដែលទៅរកនាងគ្រូទៀតទេ ? (ប្រពន្ធ លោកគ្រូ សុខុមបញ្ជាក់សួរ)

- ចាំអ្នកបង ! ឥតដែលឃើញទេ ។ ចុះឥឡូវនេះបង ប្រិកឥតនៅ ផ្ទះជាមួយលោកគ្រូ នឹងអ្នកបងទៀតទេ ( អ្នកគ្រូក្រមុំសួររកគូដណ្តឹងគេ)

- ទេ ! ប្រិកគេឈប់នៅទីនេះជិតមួយឆ្នាំទៅហើយ តាំងពីគេ ប្រឡងចូលអនុវិទ្យាល័យជាប់ម្ល៉េះ ។

- ឥឡូវនេះ បងប្រិកប្រហែលទៅស្រុកហើយមើលទៅ ព្រោះវ៉ាកង បានជាមិនមករកលោកគ្រូ ។

- ទេនាង ! គេបានមកប្រាប់ខ្ញុំថា គេឈប់រៀនហើយ ទោះខ្ញុំខំពន្យល់យ៉ាងណា ក៏វាមិនព្រមស្តាប់ទោះខំសួរវា ពីហេតុអីបានជាវាឈប់រៀនក៏វាមិននិយាយ ។ សួរណាស់ជាណាស់ទៅ វាថាវាចង់ធ្វើការ ។

-បងប្រិកឈប់រៀនយូរហើយលោកគ្រូ ( អ្នកគ្រូសួរទាំងទុក្ខព្រួយ)

- វារៀននៅអនុវិទ្យាល័យបានតែប្រហែល ៤ខែប៉ុណ្ណោះ

-ចុះលោកគ្រូមិនជ្រាបថាគាត់នៅឯណាទេសព្វថ្ងៃនេះ ?

- តាមខ្ញុំឮវាថា ប្រហែលជាវានៅភ្នំពេញឯណោះ ( ប្រពន្ធលោកគ្រូ សុខុមឆ្លើយជួស)

- នៅឯភ្នំពេញ ហេតុអ្វីមិនឃើញទៅរកខ្ញុំ ? ( អ្នកគ្រូ ភ្ញាក់)

- ព្រោះនៅថ្ងៃមួយនោះ វាមកសុំលុយបងថា ទៅប្រឡងធ្វើការខាង ក្រសួងកសិកម្ម តែគេឱ្យរៀនពីរឆ្នាំទៀតទើបបានប្រាក់ខែ បងឃាត់វាណាស់ ដែរ វាមិនព្រមសោះ ។

- ទៅរៀនខាងកសិកម្ម នៅឯណាទៅសាលានោះលោកគ្រូ ?

- អូមែន ! វាទៅរៀននៅសាលាកសិកម្មឯព្រែកលាបហើយ ព្រោះសន្យានឹងលោកគ្រូថា កាលណាវាប្រឡងធ្លាក់ វានិងត្រឡប់មករៀនវិញ បើវាប្រឡងជាប់វាឥតត្រឡប់មកវិញទេ លុះដល់វាបានចេញ ទើបវាសុំរាជការផ្លាស់ទៅស្រុក ឬក៏មកនៅខេត្តក្រចេះយើងនេះ ។

- ដូច្នេះប្រិកឥតដែលឱ្យដំណឹងអ្វីមកលោកគ្រូទេ ?

- គ្មានទេ តាំងពីវាទៅក៏បាត់តែម្តង ដូច្នេះយើងសន្និដ្ឋានថា វាច្បាស់ ជានៅរៀនឯសាលាកសិកម្មព្រែកល្បៅជាមិនខាន ។

យប់នេះអ្នកគ្រូយើងបិទភ្នែកមិនជិតទេ ព្រោះចេះតែនឹកដល់អនាគតរបស់នាង នឹងប្រិក។ នាងចង់ត្រឡប់ទៅភ្នំពេញវិញដើម្បីទៅពឹងមិត្តនាងឱ្យ ទៅស៊ើបសួររកប្រិក ហើយឱ្យគេជួយសុំទោសបងប្រិកឱ្យនាងផង ។ នាងឈប់មានចិត្តសាវ៉ាដូច្នេះទៀត ហើយនាងនឹងចាំបំរើបងប្រិកដោយភក្តីភាពលុះអវ សាននៃជីវិត។

កាលវេលាក៏ចេះតែកន្លងទៅ បវេសនកាលនៃថ្នាក់រៀនក៏បានមកដល់វិញភ្លាមដែរ ។ ឆ្នាំថ្មីនេះ អ្នកគ្រូក្រមុំយើងបានស្ម័គ្រ ចិត្តសុំរាជការផ្លាស់ទៅស្រុកកំណើតវិញ ។ នាងបានលះបង់អស់មិត្តនារីនាងនៅព្រះរាជធានី បំណងនាងដែលត្រឡប់ទៅស្រុកកំណើតគឺ ដើម្បីចង់លុបលាងអំពើដែលនាងបានប្រព្រឹត្តខុសកន្លងហួសទៅហើយ។ដែលជាហេតុនាំឱ្យប្រិកតូចដណ្តឹងប្រចាំជីវិតនាង ខូចចិត្តខានរៀនសូត្រនោះ ។ នាងសង្ឃឹមថា ថ្ងៃណានាងនិងបានជួបបង ប្រិកជាមិនខាន ហើយនាងមានសេចក្តីក្លាហាននឹងសារភាពជំរាបបងប្រិកឱ្យអស់ពីបំណងនាង ដែលនាងត្រឡប់ចូលមកភូមិកំណើតវិញ ។

គ្រួសារអ្នកគ្រូសុជាតាហៅគ្រុត មានចិត្តសោមនស្សជាទីបំផុត ជា ពិសេសទៅទៀតលោកពូមេភូមិឪពុកប្រិក ក៏ត្រេកអរណាស់ដែរកាលបើបាន ឃើញអនាគតកូនប្រសារគាត់ បានមកដល់ស្រុកវិញដូច្នោះ ។

ឆ្នាំនេះប្រិកនៅឯសាលាកសិកម្មព្រែកលាប សុជាតានៅឯជើងភ្នំ ។ គេនឹងវិលរកគ្នាវិញ ព្រោះគេបានសរសេរសំបុត្រឆ្លើយឆ្លងគ្នាសូមសារភាពនូវ កំហុសគេទៅវិញទៅមក ។ គេបានសន្យាគ្នាជាថ្មីទៀតថា គេនឹងមិនលះបង់គ្នាចោលឡើយ ទោះមានមហាឧបសគ្គយ៉ាងណាក៏ដោយ ។

មួយថ្ងៃៗ ហាក់ដូចជាយូរបំផុតសំរាប់គូនេះ ព្រោះគេទន្ទឹងឱ្យតែដាច់ ឆ្នាំអាលគេបានជួបគ្នារួមសុខទុក្ខនឹងគ្នា តែទោះយ៉ាងណាក៏ដោយក៏ព្រះអាទិត្យ ព្រះច័ន្ទ នេះតែងប្តូរផ្លាស់គ្នាបំរើមនុស្សសត្វលោកជារៀងដរាបឥតខ្ជិលច្រអូសឡើយដែរ ម្ល៉េះហើយ ១ឆ្នាំនេះ ក៏បានកន្លងផុតទៅឥតប្រឡប់ថយវិញ ។ ប្រិក បានបញ្ចប់ការសិក្សារបស់គេខាងផ្នែកកសិកម្ម និងចិញ្ចឹមសត្វនៅសាលាព្រែកលាប ហើយគេក៏ត្រូវបានរាជការផ្លាស់ទៅស្រុកវិញដូចបំណង ។

ក្រោយដែលបានរៀបមង្គលការ តាមប្រពៃណីត្រឹមត្រូវនឹងតាមទំនៀមទំលាប់ហើយគូស្វាមីភរិយាបានចាប់ដៃគ្នាបំរើផលប្រយោជន៏ដល់ជាតិ ឥតប៉ានធ្វេសឡើយ ។

អ្នកគ្រូយើង បានយកចិត្តទុកដាក់បង្ហាត់បង្រៀនសិស្សដែលជាបង ប្អូនសាច់ឈាមឥតប៉ានប្រហែស ឯប្រិកវិញក៏មិនអន់ដែរ គេបានយកចំណេះ គេខាងផ្នែកកសិកម្មចំរើនផលទៅសាបព្រោះ ដឹកនាំជនស្រុកភ្នំឱ្យចេះវិជ្ជានេះគ្រប់ៗគ្នា ។ មិនតែប៉ុណ្ណោះ ប្រិក បានតាំងខ្លួនជាអ្នក

ស្រែភ្ជួររដីបង្កើតផល ដំណាំជាគំរូដល់បងប្អូនគេទៀតផង ម្ល៉ោះហើយពេលថ្ងៃឈប់សំរាក គេរមែងឃើញអ្នកគ្រូ សុជាតាទូលបាយយកទៅឱ្យស្វាមីគេ ដែលរវល់ភ្ជួរកាប់ឆ្ការដីដាំ ដំណាំ ឥតឱ្យពេលវេលាកន្លងហួសទៅជាឥតប្រយោជន៍ឡើយ ។

ឥឡូវនេះប្រិក និងសុជាតា បានបងប្អូនខ្មែរតែងតាំងជាកសិករគំរូទៅហើយ ។

**(ចប់ដោយបរិបូណ៌)**